# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម



Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*[ នេះ] គឺជាសោកនាដកម្មរបស់របបខ្មែរក្រហម។ ពួកគេ បានធ្វើដើម្បីមូលហេតុដ៏បរិសុទ្ធ ដើម្បី បង្កើនជីវភាពប្រជាជននៅជនបទ ប៉ុន្តែ គាត់លុបបំបាត់ជីវភាពជាអ្នកក្រុង។ ប៉ុន្តែ អ្វីដែលគេធ្វើ គឺធ្វើ ឲ្យរបបទាំងមូល ឬ រដ្ឋទាំងមូលក្លាយទៅជានរកលោកិយ។*[1]

-- លោក **ហ្វីលីព ស្សុត** សាក្សីជំនាញ

## ផ្នែកទី ១ ៖ ទិដ្ឋភាពទូទៅ

នៅក្នុងរយៈពេលបួនថ្ងៃនៃកិច្ចដំណើរការនីតិវិធីសប្តាហ៍នេះ អង្គជំនុំជម្រះ បានស្តាប់សក្ខីកម្មរបស់សាក្សីជំនាញលោក **ហ្វីលីព ស្សុត** (Mr. PHILIP SHORT) ដែលជាអ្នកនិពន្ធសៀវភៅចំណងជើង "**ប៉ុល ពត: ប្រវត្តិនៃសុបិនអាក្រក់នៃប្រទេសកម្ពុជា**" លោក **ស្សុត** បានផ្តល់សក្ខីកម្មចម្បងទៅលើប្រភព និងខ្លឹមសារនៃសៀវភៅរបស់គាត់។ លោក **ហ្វីលីព ស្សុត** បានផ្តល់សក្ខីកម្មទៅលើភាពខុសគ្នានៃបញ្ហានៅក្នុងដីកាដំណោះស្រាយ ហើយបានលាតត្រដាងពីបញ្ហាដែលទាក់ទងទៅនឹងមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា គោលនយោបាយ និងការអនុវត្តន៍របស់បក្សក៏ដូចជាតួនាទី និងចរិតរបស់ជនជាប់ចោទ។ កិច្ចដំណើរការនីតិវិធី បានប្រព្រឹត្តទៅមុខដោយមានប្រសិទ្ធភាពនាសប្តាហ៍នេះ ទោះបីជាឃើញមានបញ្ហានីតិវិធីច្បាប់មួយចំនួនតូច បានកើតមានឡើងនៅពេលដែលមេធាវីការពារក្តី បានលើកឡើងនូវបញ្ហាពាក់ព័ន្ធក្នុងអំឡុងពេលនៃការសាកសួររបស់ពួកគេ។

## ផ្នែកទី ២ ៖ សក្ខីកម្មសង្ខេបរបស់សាក្សី

បន្ទាប់ពីការបោះបង់ចោលការផ្តល់សក្ខីកម្មរបស់គាត់នៅខែមីនា ឆ្នាំ២០១៣ ដោយសារតែមានការធ្វើពហិការរបស់អង្គភាពបកប្រែ និងជំងឺរបស់លោក **អៀង សារី** ប៉ុន្តែនៅសប្តាហ៍នេះ លោក **ហ្វីលីព ស្សុត** បានចូលមកបំភ្លឺនៅក្នុងសវនាការ។[2] មុនពេលការផ្តល់សក្ខីកម្មរបស់គាត់ លោក **និល ណុន** ប្រធានអង្គជំនុំ

ជម្រះសាលាដំបូងនៃ អ.វ.ត.ក បានព្រមានរំលឹកភាគីថា លោក **ហ្វីលីព ស្សុត** អាចនឹងត្រូវបានសួរសំណួរទៅលើគ្រប់ផ្នែកនៃជំនាញរបស់គាត់ ហើយភាគី គួរផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត លើអ្វីដែលពាក់ព័ន្ធទៅនឹង "សវនាការតូចៗ" នៅពេលនេះ។[3] ក្រៅពីសាវតារប្រវត្តិសាស្ត្រ ការជម្លៀសប្រជាជនលើកទី១ និងលើកទី២ និងការសម្លាប់មន្ត្រី **លន់ នល់** នៅទួលពោធិ៍ជ្រៃ និងតួនាទី ហើយនិងចរិតរបស់ជនជាប់ចោទ សាក្សីជំនាញ ក៏បានឆ្លើយសំណួរដែលបានសួរទាក់ទងទៅនឹងសហករណ៍ ការបោសសម្អាតផ្ទៃក្នុង ហើយនិងមន្ទីរសន្តិសុខ ស-២១។ លោក **ស្សុត** បានរក្សានូវគំនិតរបស់លោកថា កម្ពុជាប្រជាធិបតេយ្យជា "រដ្ឋប្រើអំណាចផ្តាច់ការ" មានន័យថា សេរីភាពផ្នែកបញ្ញា និងសេរីភាពផ្នែកប្រើប្រាស់សម្ភាររបស់បុគ្គលគ្រប់រូប ត្រូវបានគេដកហូតដើម្បីបង្កើតជាតិមួយដែលមានភាពស្មើគ្នា និងបំបាត់ភាពជាឯកជន។

នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជា បានរៀបចំនូវគោលដៅដ៏ថ្លៃថ្លានៃការបង្កើតប្រទេសជាតិឱ្យមានការរីកចម្រើនរុងរឿង តាមរយៈការរួបរួមគ្នានៃគោលជំហរជាឆ្លុងមួយ ដែលមើលមិនឃើញពីទុក្ខលំបាករបស់ប្រជាជន។ ពួកកម្មាភិបាលអសមត្ថភាព និងការភ័យខ្លាចមិនទុកចិត្តគ្នាទៅវិញទៅមក បណ្តាលឲ្យរបបមួយនេះ បានបាត់បង់ និងបង្កនូវភាពឈឺចាប់យ៉ាងក្រៃលែងទៅលើប្រជាជន។ ទាក់ទងទៅនឹងតួនាទីរបស់សហជនជាប់ចោទ លោក **ស្សុត** បានសន្និដ្ឋានពីប្រភពដែលគាត់បានពិភាក្សាថា លោក **នួន ជា** គឺជាមិត្តសម្លាញ់របស់ **ប៉ុល ពត**។ បើទោះបីជាទំហំនៃទំនាក់ទំនងរវាងអ្នកទាំងពីរនេះ គឺមានការលំបាកក្នុងការស្រាវជ្រាវឱ្យឃើញក៏ដោយ។ អ្នកជំនាញ បានពិពណ៌នាថា លោក **ខៀវ សំផន** ជាបរិវារដ៏ប្រសើរជាជាងធ្វើជាមេដឹកនាំ ដែលប្រហែលជាមិនមានអំណាចក្នុងការធ្វើសេចក្តីសម្រេចទេ ប៉ុន្តែ **ប៉ុល ពត** ឬ **នួន ជា** មានអំណាច ហើយលោក **ខៀវ សំផន** ក៏មិនបានតវ៉ាប្រឆាំងនឹងការសម្រេចចិត្តរបស់ពួកគេ។

## ក. សក្ខីកម្មរបស់សាក្សី

លោក **ហ្វីលីព ស្សុត** អាយុ ៦៨ ឆ្នាំ ជាជាតិអង់គ្លេស ដែលធ្លាប់មានបទពិសោធន៍ជាអ្នកកាសែត និងជាអ្នកប្រវត្តិសាស្ត្រ ហើយក៏ជាអ្នកនិពន្ធជីវប្រវត្តិ ដែលមានបទពិសោធន៍អស់រយៈពេលជាង ៤០ ទៅ ៤៥ ឆ្នាំ។ លោក **ស្សុត** គឺជាអតីតបុគ្គលិករបស់ស្ថានីយទូរទស្សន៍ ប៊ី.ប៊ី.ស៊ី (BBC) ដែលថែមទាំងធ្លាប់ជាអ្នកយកព័ត៌មានបរទេសប្រចាំទីក្រុងប៉េកាំងក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ទៀតផង។ អ្នកជំនាញ បានសរសេរសៀវភៅអំពីមេដឹកនាំជាច្រើននៃបណ្តាប្រទេសមួយចំនួន ហើយក្នុងនោះរួមមាន៖ ប្រទេសចិន សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត និងប្រទេសកម្ពុជា។ សំខាន់ជាងនេះទៀត គាត់បានសរសេរសៀវភៅមួយដែលមានចំណងជើងថា "ប្រវត្តិនៃសុបិនអាក្រក់នៃប្រទេសកម្ពុជា" (តទៅហៅថា "សៀវភៅប្រវត្តិសាស្ត្រ") ដែលយកមកប្រើប្រាស់ជាភស្តុតាងក្នុងសំណុំរឿង ០០២/០១ និងជាមូលដ្ឋានចម្បងសម្រាប់សាកសួរមកលើគាត់ដោយភាគីទាំងឡាយ។

## ខ. ទំនាក់ទំនងរវាងប្រទេសវៀតណាម និងរបប សម្តេចសីហនុ

លោក **តារីក អាប់ឌុលហាក់ (**Mr. Tarik Abdulhak**)** ដែលជាសហព្រះរាជអាជ្ញាអន្តរជាតិ បានសង្ខេបពី "សៀវភៅប្រវត្តិសាស្ត្រ" អំពីការវិវត្តន៍នៃលទ្ធិកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០។ សៀវភៅរបស់លោក **ស្សុត** បានពិពណ៌នាពីចលនាកុម្មុយនីស្តគឺ "ស្ថិតនៅក្រោមការឧបត្ថម្ភទូទៅ"

របស់ប្រទេសវៀតណាម។ ចលនាកុម្មុយនីស្តនៅពេលនោះ មានគណៈកម្មាធិការជាច្រើនរួមមាន គណៈកម្មាធិការទីក្រុង ដែល **ប៉ុល ពត** និង **នួន ជា** បានចូលបម្រើការងារក្នុងឆ្នាំ១៩៥០។ លោកសហព្រះរាជអាជ្ញាអន្តរជាតិ បានសួរលោក **ស្បេត** ឱ្យពន្យល់លម្អិតអំពីការប្រជុំសមាជ ដែលបានធ្វើនៅក្នុងខែកញ្ញា ឆ្នាំ១៩៦០ ដែលចូលរួមដោយគណៈប្រតិភូចំនួន ២១រូប។ "សៀវភៅប្រវត្តិសាស្ត្រ" នេះ បានពិពណ៌នាកម្មវិធី ដែលបានសម្រេចនៅក្នុងកិច្ចប្រជុំនេះថាជា "វាជាចំណុចចាប់ផ្តើមដែលមាគ៌ានៃបក្សកុម្មុយនីស្តកម្ពុជា ឈានទៅរកឯករាជ្យរបស់ខ្លួននោះ" ចេញពីប្រទេសវៀតណាម។[4] អ្នកជំនាញបានពន្យល់ថា នៅក្នុងសមាជឆ្នាំ១៩៦០ ប្រជាជនកម្ពុជាបានសម្រេចចិត្តរៀបចំសមាជរបស់ពួកគេផ្ទាល់ ដោយមិនចាំបាច់មានការអញ្ជើញ ឬការជូនដំណឹងដល់វៀតណាមទេ។ ដំណើរការនៃការផ្តាច់ខ្លួនចេញពីវៀតណាមនេះ គឺជារឿងដែលនៅតែបន្ត ហើយនិងបានកើតឡើងចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៤០ ក្នុងអំឡុងពេលដែលចលនាតស៊ូប្រឆាំងនឹងប្រទេសបារាំង។ ហេតុផលដ៏សំខាន់ ទីមួយសម្រាប់ការផ្តាច់ខ្លួននេះ បើយោងតាមអ្នកជំនាញ គឺវៀតណាមមានបំណងប្រាថ្នាចង់ឱ្យគេឃើញខ្លួនថាជា "បងប្រុស" និងការគ្រប់គ្រងរបស់ពួកគេនៅលើប្រទេសកម្ពុជា។ ហេតុផលទីពីរ គឺមានភាពខុសគ្នាលើការចាប់អារម្មណ៍ទាក់ទងទៅនឹងរបប **សម្តេចសីហនុ**។ ពួកកុម្មុយនីស្តវៀតណាមបានយល់ឃើញ **សម្តេចសីហនុ** ជាសម្ព័ន្ធមិត្ត ដែលបានជួយជ្រោមជ្រែងផលប្រយោជន៍របស់ពួកគេនៅក្នុងសង្គ្រាមវៀតណាម។ ពួកកុម្មុយនីស្តកម្ពុជា ដែលត្រូវបានទទួលរងពីវិធីសាស្ត្រវិតត្បិតកាន់តែខ្លាំងឡើងលើការប្រឆាំងជំទាស់នានារបស់ពួកគេ បានចាត់ទុកថា **សម្តេចសីហនុ** ជាសត្រូវទៅវិញ។

លោក **ស្បេត** បានបញ្ជាក់ថា ការប្រជុំពេញអង្គរបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ១៩៦៤ និងនៅក្នុងឆ្នាំ១៩៦៥ គឺជាជំហានបន្ថែមទៀតនៅក្នុងការព្យាយាម ដើម្បីឱ្យមានឯករាជ្យ។[5] កិច្ចប្រជុំ បានសម្រេចឲ្យមានដំណោះស្រាយ ដោយអះអាងពីអំពើបដិវត្តន៍ដោយហិង្សា នៅក្នុងការតស៊ូប្រឆាំងនឹង "ពួកចក្រពត្តិនិយម និងបាវព្រាវរបស់ខ្លួន" ជាមួយ **សម្តេចសីហនុ** ដែលត្រូវបានចាត់ជាមនុស្សម្នាក់ក្នុងចំណោមពួកចក្រពត្តិនិយម។ អ្នកជំនាញបានបន្ថែមថា បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានបង្ខំឱ្យងាកទៅប្រើអំពើហិង្សា ព្រោះតែ **សម្តេចសីហនុ** បានបិទចន្លោះរាល់សកម្មភាពស្របច្បាប់ចំពោះគណបក្សប្រឆាំង។

មានចំណុចមួយ គឺនៅពេលដែលប្រទេសវៀតណាម បានបញ្ឈប់ការផ្គត់ផ្គង់អាវុធយុទ្ធភណ្ឌរបស់ខ្លួន ទៅឱ្យខ្មែរក្រហម។ យ៉ាងណាក៏ដោយ នៅឆ្នាំ១៩៧៣ ពួកគេត្រូវបានប្រឈមមុខជាមួយនឹងការពិតដែលថា ខ្មែរក្រហមបានយកឈ្នះ និងបានកាន់កាប់មួយផ្នែកដ៏សំខាន់នៃទឹកដីរបស់ប្រទេសកម្ពុជា។ ដោយពេលនោះ វាទំនងជាពួកបក្សកុម្មុយនីស្តកម្ពុជា អាចយកឈ្នះសង្គ្រាមនេះបាន ទោះបីជាមាន ឬគ្មានការគាំទ្រពីក្រុងហាណូយ។ ដោយត្រូវជ្រើសរវាងការបន្តព្យាយាមបង្ខំឱ្យខ្មែរក្រហម "ស្តាប់តាមឆន្ទៈរបស់ទីក្រុងហាណូយ" ឬ ខ្លួនត្រូវបន្តការគាំទ្រដល់ពួកខ្មែរក្រហមនោះ នៅទីបំផុតប្រទេសវៀតណាម បានរើសយកជម្រើស គឺបន្តការផ្គត់ផ្គង់អាវុធ។ ក្រៅពីប្រទេសវៀតណាម ខ្មែរក្រហមក៏បានទទួលអាវុធយុទ្ធភណ្ឌមកពីប្រទេសចិន និងមន្ត្រី **លន់ នល់** ដែលពុករលួយផងដែរ។

## គ. សមាសភាពរបស់បក្សកុម្មុយនីស្តកម្ពុជា

អ្នកជំនាញបានឱ្យដឹងថា ចាប់ផ្តើមពីថ្ងៃបង្កើតបក្សកុម្មុយនីស្តដោយសម្ងាត់មក "អង្គការ" ត្រូវបានប្រើដើម្បីសំដៅទៅលើបក្សកុម្មុយនីស្តនោះ។ ដំបូងឡើយ ក្រុមនេះត្រូវបានគេហៅថា បក្សកុម្មុយនីស្តខ្មែរ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ គណបក្សរួមមាន អតីតតស៊ូរជននៅតាមជនបទ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ បានឃើញការកើនឡើងនៃសមាជិកដែលជាសិស្សនិស្សិត បានវិលត្រឡប់មកពីបរទេស។ សមាជិកពេញលេញនៃគណៈអចិន្ត្រៃយ៍ ដែលជាប់ឆ្នោតនៅក្នុងឆ្នាំ១៩៦០ រួមមានលោក **នួន ជា, ប៉ុល ពត** និង **អៀង សារី** (ដែលបានវិលត្រឡប់មកពីប្រទេសបារាំង) ហើយនិង **សោ ភិម** "មេកន្ទ្រាញនៅតាមជនបទ"។ លោក **ស្បូត** បានពន្យល់ថា "ផ្ទះថ្ម" (ពួកនិស្សិតត្រឡប់មកទីក្រុង) "ផ្ទះស្បូវ" (អតីតពួកតស៊ូរ) ក៏ដូចជាជនជាតិភាគតិច "តូច" មកពីក្រុមថៃ ដែលមានលោក **នួន ជា** ស្ថិតនៅក្នុងក្រុមនោះ មានសមាសភាពជាថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្ត។ លោក **ស្បូត** បានពន្យល់ថា ការរួបរួមក្នុងចំណោមក្រុមទាំងនេះ "មិនដែលបានកើតឡើងទាំងស្រុង" នោះទេ ហើយការប៉ះទង្គិចគ្នារវាងពួកគេ បានតស៊ូយ៉ាងស្អុគស្មាញទៅវិញទៅមកក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះពីដើមដល់ចប់។ លោកក៏បានរម្លឹកថា **ខៀវ សំផន** បានស្តីបន្ទោសអំពើឃោរឃៅ ដែលបានកើតឡើងចំពោះ "អតីតតស៊ូរជន" ដែលជនជាប់ចោទបានពណ៌នាថាជា "កំពូលអ្នកធ្វើសឹក"។ ទោះជាយ៉ាងណាក៏ដោយ អ្នកជំនាញបានគូសបង្ហាញថា មានភស្តុតាងដែលអតីតតស៊ូរជននេះ ពិតជាបានគោរពតាមគោលនយោបាយរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាយ៉ាងខ្ជាប់ខ្ជួន។

## ឃ. ការវាយប្រហារមកលើទីក្រុងភ្នំពេញ

លោក **ស្បូត** បាននិយាយថា ការវាយប្រហារដោយបរាជ័យរបស់ពួកខ្មែរក្រហម មកលើទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៧៣ ត្រូវបានជម្រុញជាចម្បងដោយក្តីប្រាថ្នារបស់ **ប៉ុល ពត** ចង់ដណ្តើមយកទីក្រុងភ្នំពេញឱ្យបាន មុនពេលការទម្លាក់គ្រាប់បែករបស់អាមេរិកបានបញ្ចប់។[6] នៅក្នុង "សៀវភៅប្រវត្តិសាស្ត្រ" របស់លោក **ស្បូត** បានសរសេរថា បន្ទាប់ពីការវាយប្រហារបានទទួលបរាជ័យ **ប៉ុល ពត** បានផ្លាស់ទីកន្លែងទៅកាន់ឧត្តុង្គ-តាមផ្លូវទៅខេត្តពោធិ៍សាត់ ដែលមានចម្ងាយ ៣០គីឡូម៉ែត្រពីភ្នំពេញ។ លោក **ស្បូត** បានអះអាងថា ការវាយប្រហារដោយការបំផ្លោងគ្រាប់បែកទៅលើទីក្រុងនៅក្នុងឆ្នាំ១៩៧៣ គឺជាការប៉ុនប៉ងមួយទៅលើសង្គ្រាមផ្លូវចិត្តដើម្បីបង្ហាញថា របប **លន់ នល់** មិនអាចការពារនរណាម្នាក់បាននោះទេ។ លោក **ស្បូត** ពន្យល់ថា ហេតុការណ៍បំផ្លោងគ្រាប់បែកទាំងនេះ ជារឿយៗធ្លាក់ចំអ្នកក្រីក្ររស់នៅតាមជាយក្រុង គឺអាចទទួលយកបាន ដោយសារប្រជាជនបានជ្រើសរើសមិនចូលរួមបដិវត្តន៍ និងសុខចិត្តនៅជាមួយ **លន់ នល់**។

## ង. មនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា និងការភ័យខ្លាចមិនទុកចិត្តគ្នាទៅវិញទៅមក

លោក **ស្បូត** បានរៀបរាប់នៅក្នុង "សៀវភៅប្រវត្តិសាស្ត្រ" របស់គាត់ថា បក្សកុម្មុយនីស្ត ជាការចាប់ផ្តើម "ការធ្វើបដិវត្តន៍ផ្លាស់ប្តូរទាំងស្រុងមួយ" នៅលើពិភពលោក។[7] លោកបានពន្យល់ទៅកាន់លោក **វេង ហួត** សហព្រះរាជអាជ្ញាជាតិថា គ្មានគណបក្សកុម្មុយនីស្តមួយណាបានធ្វើទេ សូម្បីតែគណបក្សកុម្មុយនីស្តនៅក្នុងប្រទេសកូរ៉េខាងជើង ប្រទេសចិន ឬសហភាពសូវៀត មិនដែលធ្លាប់បានព្យាយាមផ្លាស់ប្តូរយ៉ាងឆាប់

របៀបសបែបនេះ ដើម្បីឈានដល់រដ្ឋកុម្មុយនីស្តតាមបែបលទ្ធិម៉ាក្សស៊ីសនិយមពិតប្រាកដ ដែលរដ្ឋមួយមានភាពស្មើគ្នាពេញលេញនោះទេ។ លោក **ស្វត** បានបញ្ជាក់ថា ការសម្រេចចិត្តផ្លោះទៅរកលទ្ធិកុម្មុយនីស្តសុទ្ធសាធភ្លាមៗបែបនេះ ត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំមេដឹកនាំបក្សកុម្មុយនីស្តមួយនៅខែឧសភាឆ្នាំ ១៩៧៥ នៅព្រះវិហារព្រះកែវមរកតនៅទីក្រុងភ្នំពេញ។

លោក **ស្វត** បានយល់ស្របជាមួយនឹងសៀវភៅរបស់លោក **ស្ទីវ ហេដឌ័រ** (Mr. Stephen Heder) ដែលមានចំណងជើង "លទ្ធិកុម្មុយនីស្តកម្ពុជា និងគំរូតាមបែបប្រទេសវៀតណាម" ថា មនោគមន៍វិជ្ជាបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានយកគំរូភាគច្រើនតាមប្រទេសវៀតណាម។ ប៉ុន្តែលោក **ស្វត** បានយល់ខុសពីលោក **ហេដឌ័រ** នៅត្រង់គំរូដ៏ធំ បានយកតាមបែបប្រទេសវៀតណាមទៅវិញ ដែលបក្សកុម្មុយនីស្តនេះ ត្រូវបានរៀបចេញជារូបរាងផ្ទាល់ដោយបក្សវៀតណាម។ លោក **ស្វត** បានជឿជាក់ថា បក្សកុម្មុយនីស្តកម្ពុជាបានទទួលឥទ្ធិពលបន្ថែមទៀតពីវប្បធម៌ខ្មែរ និងផ្នត់គំនិតពុទ្ធសាសនា នាំឱ្យខុសគ្នាពីគណបក្សកុម្មុយនីស្តផ្សេងទៀត។ គាត់ក៏បានបន្តទៀតថា គ្រឹះរបស់បក្សកុម្មុយនីស្តរួមមាន សម្ព័ន្ធភាពវណ្ណៈកសិករខ្មែរ និងបញ្ញវន្តដោយឡែកមិនពាក់ព័ន្ធផ្ទាល់ជាមួយនឹងអ្នកធ្វើការ ឬអ្នកគេងផលប្រយោជន៍ពីកម្លាំងអ្នកដទៃ។ ទាំងនេះ គឺបានធ្វើឱ្យបក្សកុម្មុយនីស្តកម្ពុជា ខុសគ្នាពីបក្សកុម្មុយនីស្តដទៃទៀត ដែលបានយកគំរូតាមបក្សលេនីននិយម មានដូចជា បក្សកម្មករវៀតណាម។ បក្សកុម្មុយនីស្តកម្ពុជា ក៏ខុសគ្នាពីគំរូលទ្ធិម៉ាក្សលេនីននិយមផងដែរ ដោយខ្វះខាតនូវពេលវេលាអន្តរកាលមួយ ដើម្បីទាក់ទាញអ្នកដែលមិនប្រឆាំងនឹងបដិវត្តន៍មុននឹងមានការផ្លាស់ប្តូរទាំងស្រុងបានកើតឡើង។

លោក **ស្វត** បានពន្យល់ប្រាប់ថា ការសម្ងាត់ គឺជាចរិតលក្ខណៈរបស់មេដឹកនាំខ្មែរក្រហមដោយសារ តែហេតុផលជាក់ស្តែង ក៏ដូចជាវប្បធម៌ខ្មែរផងដែរ។ ឧទាហរណ៍ ក្នុងឆ្នាំ១៩៦៦ បក្សកម្មករកម្ពុជាបានប្តូរឈ្មោះទៅជាបក្សកុម្មុយនីស្តកម្ពុជា ជាការពិតនោះ គឺត្រូវបានរក្សាទុកជាការសម្ងាត់ ដើម្បីបង្ការកុំឱ្យមានភាពមិនចុះសម្រុងជាមួយនឹងបក្សកម្មករវៀតណាម។ ឈ្មោះមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ក៏ត្រូវបានគេរក្សាទុកដោយសម្ងាត់ផងដែរ ដោយសារតែការភ័យខ្លាចមិនទុកចិត្តគ្នាទៅវិញទៅមក ដោយសារតែមួយផ្នែកនៃប្រទេសកម្ពុជា មានព្រំដែនជាប់ជាមួយប្រទេសជិតខាងដ៏ខ្លាំងដូចជាប្រទេសថៃ និងវៀតណាម មិនតែប៉ុណ្ណោះ ថែមទាំងមានការភ័យខ្លាចខ្លាំងផ្ទៃក្នុងផងដែរ។

លោក **វិចទ័រ កូប៉េ** (Mr. Victor Koppe) សហមេធាវីអន្តរជាតិការពារឲ្យលោក **នួន ជា** បានសួរអ្នកជំនាញថា តើការភ័យខ្លាចខ្លាំងផ្ទៃក្នុងអាចហៅបានថាជា "ការភ័យខ្លាចមិនទុកចិត្តគ្នាទៅវិញទៅមក" នៅពេលដែលពួកកម្មាភិបាលដូចជា លោក **ហេង សំរិន** និងលោក **ហ៊ុន សែន** បានរត់ចោលស្រុកទៅចុះចូលនឹងវៀតណាមឬយ៉ាងណា។ លោក **ស្វត** បានរក្សាជំហរថា លោក **ហេង សំរិន** បានលួចរត់ចោលស្រុក នៅចំពេលដែលការបោសសម្អាតផ្ទៃក្នុងរឹតតែធ្ងន់ធ្ងរឡើង ខណៈពេលដែលអ្នកលួចរត់ចោលស្រុកខាងលើ មានហេតុផលផ្ទាល់ខ្លួនរបស់ពួកគេ។ លោក **ស្វត** បានអះអាងថាការពិត គ្មានភាគីផ្ទៃក្នុងខាងណា រួមគំនិតគ្នាក្បត់ជាមួយនឹងកងកម្លាំងខាងក្រៅ ដើម្បីផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ ទោះបីជា ប្រទេសវៀតណាម មានមហិច្ឆតាចង់គ្រប់គ្រងទឹកដីឥណ្ឌូចិន ដែលនៅសេសសល់ទាំងអស់ ក៏បានចាប់ផ្តើមធ្វើការវាយប្រហារ ដោយសារតែទំនាក់ទំនងជាមួយកម្ពុជាកាន់តែអាក្រក់ឡើងទៅ។

## ច. រចនាសម្ព័ន្ធរដ្ឋបាល

ដោយយោងទៅលើការដកស្រង់ខ្លីៗនៅក្នុង "សៀវភៅប្រវត្តិសាស្ត្រ" លោក **អាប់ឌុលហាក់** បាន លើកឡើងពីការសម្រេចចិត្តថ្នាក់រដ្ឋបាល ដែលធ្វើឡើងនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្ត កម្ពុជា នៅឯខេត្តកំពង់ធំ រួមទាំងការសម្រេចចិត្តលើព្រំដែនសម្រាប់ភូមិភាគ ការបំលែងលេខកូដ និងការ បង្កើតភូមិភាគពិសេសនៅជុំវិញរាជធានីភ្នំពេញក្រោមការគ្រប់គ្រងរបស់ **វន វ៉េត**។[8] ភូមិភាគនីមួយៗ ត្រូវបានបំបែកទៅជាតំបន់ដែលមានលេខកូដរបស់ខ្លួន។ ក្នុងអំឡុងពេលកិច្ចប្រជុំកងកម្លាំងយោធាត្រូវបាន រៀបចំឡើងវិញតាមគំរូវៀតមិញដូចជា៖ ការដើរយាមល្បាតក្នុងភូមិ កងទ័ពក្នុងតំបន់មានមុខងារនៅថ្នាក់ ស្រុក និងអង្គភាពកម្លាំងដ៏សំខាន់ ដែលត្រូវបានរៀបចំនៅក្នុងតំបន់នេះ។ លោក **ស្បុត** បានផ្តល់សក្ខីកម្ម ថា ការសម្រេចចិត្តទាំងនេះមានសារៈសំខាន់ ពីព្រោះពួកគេ គឺជាអ្នកឆ្លើយតបទៅដើម្បីផ្លាស់ប្តូរស្ថានភាពនៃ បក្សកុម្មុយនីស្តនេះ។ ដើមឡើយ វាគឺជាបក្សតូចមួយដែលមានចំនួនសមាជិកភាពតិចតួច ប៉ុន្តែ បន្ទាប់ពី វៀតណាម បានចូលមកក្នុងទឹកដី និងបានផ្តល់ការគាំទ្រមួយផ្នែកធំនៃទឹកដីរបស់ប្រទេសកម្ពុជា ក៏បានស្ថិត នៅក្រោមការត្រួតពិនិត្យរបស់ពួកកុម្មុយនីស្ត។ បក្សកុម្មុយនីស្តកម្ពុជា ត្រូវបង្កើតរចនាសម្ព័ន្ធដែលអនុញ្ញាត ឱ្យពួកគេគ្រប់គ្រងទឹកដីនេះ បន្ទាប់ពីការចាកចេញរបស់វៀតណាម។ លោក **ស្បុត** បានបញ្ជាក់ថានៅក្នុងឆ្នាំ ១៩៧៣ មន្ទីរសន្តិសុខត្រូវបានគេបង្កើតឡើងនៅក្នុងភូមិភាគពិសេស។ ជាមួយនឹងការបង្កើតមន្ទីរពេទ្យមួយ កន្លែងស្របគ្នា វាជាការបង្កឲ្យមានការចាប់ផ្តើមដំបូងនៃផ្នែករដ្ឋបាល។

អ្នកស្រី **អង់តា ហ្គីសសេ** (Ms. Anta Guissé) សហមេធាវីអន្តរជាតិការពារឲ្យលោក **ខៀវ សំផន** បានសំដៅចំពោះតំណែងរបស់លោក **ខៀវ សំផន** នៅក្នុងរដ្ឋាភិបាលថាជា "តំណែងខ្មោច" ដែលបាន ប្រកាសនៅក្នុងខែមករា ឆ្នាំ១៩៧៥ បួនខែមុនពេលដែលភ្នំពេញដួលរលំ។[9] លោក **ស្បុត** បានពន្យល់ ថា សេចក្តីប្រកាសនេះ ត្រូវបានធ្វើឡើងមិនត្រឹមតែដើម្បីរក្សាការសម្ងាត់នោះទេ តែក៏ដើម្បីបង្ហាញថា មានរដ្ឋា ភិបាលមួយដែលដំណើរការត្រៀមខ្លួនជាស្រេច ដើម្បីឡើងកាន់តំណែងបន្ត។ លោក **ស្បុត** បានបន្តទៀតថា ចាប់តាំងពីការបង្កើតឡើងនៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជានៅឆ្នាំ ១៩៧១ មក ការប្រកាសថា រដ្ឋាភិបាលបានបង្កើតឡើងនោះ "គឺជាការប្រឌិតឡើងទាំងស្រុង។" តំណែងនៅ ក្នុងក្រសួងនានា គឺមានតែនៅលើក្រដាសប៉ុណ្ណោះ ហើយនិងការប្រើប្រាស់បន្លំឲ្យជឿបែបនេះ ត្រូវបានធ្វើ ឡើងពេញមួយរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ឧទាហរណ៍ ការពិត រដ្ឋសភាជាតិ មិនមាននោះ ទេ។

លោកស្រី **ស៊ីលវៀ ខាតរ៉ាយថ៍** (Judge Silvia Cartwright) សហចៅក្រមអន្តរជាតិ បានលើកឡើង ពីរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា ដូចដែលបានបង្ហាញនៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តផងដែរនៅក្នុង ឆ្នាំ១៩៧៥។ លក្ខន្តិកៈបានចែងថា ការធ្វើមហាសន្និបាតគឺជា "សិទ្ធិអំណាចដ៏ខ្ពស់បំផុតទូទាំងប្រទេស" នៅ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គណៈអចិន្ត្រៃយ៍ គឺកោះហៅឲ្យមានមហាសន្និបាត ហើយឲ្យបានយ៉ាងហោច ណាស់ជារៀងរាល់បួនឆ្នាំម្តង។ លោក **ស្បុត** បានពន្យល់ថា "មហាសន្និបាត" គឺស្មើនឹង "សមាជបក្ស" នៅក្នុង ប្រព័ន្ធរបស់បក្សកុម្មុយនីស្តដទៃទៀត។

ចំពោះគណៈអចិន្ត្រៃយ៍ លោក **ស្បូត** បានផ្ដល់សក្ខីកម្មថា **ប៉ុល ពត** បានក្លាយជាលេខាធិការនៃគណៈអចិន្ត្រៃយ៍នៅក្នុងឆ្នាំ១៩៦៣។ ក្រោយមក **ប៉ុល ពត** បានក្លាយជាលេខាធិការរបស់បក្សនេះ។ អង្គការនេះ មានអំណាចខ្លាំងបំផុតនៅតាមឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា ដែលមានសិទ្ធិអំណាចដើម្បីតែងតាំងមន្ត្រីជាន់ខ្ពស់ក្នុងបក្សរដ្ឋាភិបាល និងកងទ័ព។ អង្គការនេះ ក៏មានអំណាចដើម្បីឃ្លាំងមើល និងផ្ទៀងផ្ទាត់ការអនុវត្តន៍ចំពោះគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដោយឡែក ថាតើមុខងារទាំងនេះត្រូវបានអនុវត្តជាលក្ខណៈប្រព័ន្ធ ឬក៏អត់ "គឺជាបញ្ហាផ្សេង"។ លោក **ស្បូត** បានប្រកាន់ជំហរថា អង្គភាពដែលមានបញ្ហាលើប្រតិបត្តិការប្រចាំថ្ងៃរបស់បក្សកុម្មុយនីស្តកម្ពុជា គឺគណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការមន្ទីរសន្តិសុខ។ ក្រោយមក គណៈកម្មាធិការមន្ទីរសន្តិសុខ មានតួនាទីគ្រប់គ្រងមន្ទីរស-២១ ហើយមានដូចជា **ប៉ុល ពត, សុន សេន** និង **នួន ជា** ជាសមាជិកគណៈកម្មាធិការ។

បើប្រៀបធៀបរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជាជាមួយនឹងបក្សកុម្មុយនីស្តដទៃទៀត លោក **ស្បូត** បានពិពណ៌នាថា វាមិនដូចជាបក្សកុម្មុនីស្តដទៃទៀតទេ។ លោកបានទទួលស្គាល់ថា វាដូចជាបក្សដទៃទៀត អំណាចធ្វើសេចក្ដីសម្រេចចិត្តចុងក្រោយក្នុងបក្សកុម្មុយនីស្តកម្ពុជា គឺស្ថិតនៅក្នុងដៃរបស់បក្ស គឺជាគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ឬក្រុមដ៏សំខាន់របស់រដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ នៅប្រទេសកម្ពុជា រចនាសម្ព័ន្ធ មិនមែនជាលក្ខណៈប្រព័ន្ធនោះទេ ដោយមានការបញ្ចូលគ្នាតែមួយនៃតួនាទីនានារវាង **នួន ជា** និង**ប៉ុល ពត**។ លោក **ស្បូត** បានរៀបរាប់ថា គណៈកម្មាធិការមជ្ឈិមបក្ស ក៏ជាសមាជិកជួយជំរុញក្នុងការធ្វើសេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃឲ្យមានភាពស្របច្បាប់។ លោក **ស្បូត** បានផ្ដល់ចម្លើយថា គណៈអចិន្ត្រៃយ៍ជាច្រើន និងសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស គឺគ្មានទីតាំងនៅទីក្រុងភ្នំពេញទេ ដោយសារតែដែលពួកគេ គឺជាមេដឹកនាំនៅថ្នាក់ខេត្ត។

លោក **ស្បូត** បានផ្ដល់សក្ខីកម្មថា មិនដូចរយៈកាលមុនពេលភ្នំពេញដួលរលំទេ ក្រសួងមួយចំនួនដូចជា ក្រសួងការការពារជាតិ ក្រសួងការបរទេស និងក្រសួងសង្គមកិច្ច គឺមានអំណាចខ្លាំងណាស់។ ទោះជាយ៉ាងណាក៏ដោយ អំណាចក្នុងការធ្វើសេចក្ដីសម្រេចចិត្ត គឺស្ថិតនៅក្នុងដៃគណៈអចិន្ត្រៃយ៍ ហើយក្រសួងមិនមែនជាស្ថាប័នសម្រាប់បង្កើតគោលនយោបាយនោះទេ។ ក្រសួងការពារជាតិ ដែលស្ថិតនៅក្រោម **សុន សេន** គឺគ្រប់គ្រងកងទ័ពបដិវត្តន៍ ប៉ុន្តែកងទ័ពបដិវត្តន៍កម្ពុជា ជាអ្នកធ្វើរបាយការណ៍ទៅកាន់គណៈអចិន្ត្រៃយ៍ ហើយមេដឹកនាំភូមិភាគ និងមេបញ្ជាការយោធានឹងបញ្ជូនទូរលេខទៅកាន់ការិយាល័យ ៨៧០។

ទាក់ទងទៅនឹងការិយាល័យលេខ ៨៧០ លោក **ស្បូត** បានរៀបរាប់ថា ការិយាល័យនេះ គឺស្មើនឹងការិយាល័យគណៈកម្មាធិការមជ្ឈិមបក្សដូចក្នុងបណ្ដាប្រទេសដទៃទៀត។ ចំពោះការិយាល័យមួយនេះជា "តំបន់បញ្ជូនមួយ" ដែលអ្នកជំនាញបានឃើញការិយាល័យនេះថា មានសារៈសំខាន់ខ្លាំងសម្រាប់អនុវត្តន៍រាល់ការសម្រេចចិត្តរបស់គណៈអចិន្ត្រៃយ៍។ លោក **ស្បូត** ក៏បានជឿផងដែរថា ការិយាល័យគ្រប់គ្រងព័ត៌មានគឺនៅជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា។

លោក **ហ្វីលីព ស្បូត** ត្រូវបានសួរឱ្យផ្ដល់យោបល់ទៅលើសក្ខីកម្មរបស់លោក **ដេវីដ ឆេនដ័ល័រ** (Mr. David Chandler) នៅមុខអង្គជំនុំជម្រះ ដែលគាត់បានថ្លែងថា ថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យមាន

លក្ខណៈជាសមូហភាពច្រើនជាងអ្វីដែលគាត់បានគិតទុក។[10] លោក **ស្សុត** បានថ្លែងថា ខ្លួនលោកជឿជាក់ថា **ប៉ុល ពត** ជាអ្នកធ្វើការសម្រេចចិត្ត ហើយប្រហែលជាបានប្រើប្រាស់ និងចាត់ចែងឲ្យការសម្រេចចិត្តរបស់គាត់ ឲ្យបានអនុម័តជាសមូហភាពរួមមួយ។ លោក **ស្សុត** ក៏ជឿថាលោក **នួន ជា** បានចូលរួមក្នុងការធ្វើការសម្រេចចិត្តទោះបីជាគាត់ មិនបានដឹងដល់កម្រិតណាក៏ដោយ។

## ឆ. រចនាសម្ព័ន្ធទំនាក់ទំនង

រាល់កិច្ចប្រជុំរបស់ខ្មែរក្រហម លោក **ស្សុត** បាននិយាយថា មានកិច្ចប្រជុំស្តីអំពីរបៀបរស់នៅ និងស្វ័យទិតៀន ហើយក៏ពាក់ព័ន្ធពីគោលការណ៍របស់បក្សដែរ។ ចំពោះការពិភាក្សាលើគោលការណ៍វិញ លោក **ស្សុត** បានពន្យល់ថា ត្រូវបានធ្វើឡើងនៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស ឬនៅតាមកិច្ចប្រជុំសាខាបក្ស។

លោក **ស្សុត** បានផ្តល់សក្ខីកម្មទៅលើរចនាសម្ព័ន្ធទំនាក់ទំនង និងការទទួលបានព័ត៌មានច្រើនប៉ុណ្ណារបស់មេដឹកនាំបក្សកុម្មុយនីស្តពីថ្នាក់ក្រោមនោះ? លោកបានពន្យល់ថា ទូរលេខ គឺត្រូវបានគេបញ្ជូនមកពីភូមិភាគនានាទៅកាន់គណៈកម្មាធិការមជ្ឈិមបក្ស។ គណៈកម្មាធិការមជ្ឈិមបក្ស ត្រូវបានជូនដំណឹងអំពីបញ្ហានៅក្នុងតំបន់មួយចំនួន បើទោះបីជាទូរលេខ មិនបានបញ្ជាក់ថា ការលំបាកនោះបណ្តាលមកពីកំហុសនៅក្នុងគោលនយោបាយ ប៉ុន្តែបែបជាដាក់កំហុសថា មិនព្រមធ្វើតាមទើបបណ្តាលឲ្យខូចខាត និងមានបញ្ហាលំបាកកើតឡើង។ អ្នកជំនាញ ក៏បានរៀបរាប់ដំណើរទស្សនកិច្ចសិក្សា ដោយសំដៅទៅលើ ទស្សនកិច្ចរបស់ **អៀង ធីរិទ្ធ** ទៅកាន់ភូមិភាគខាងជើង និងភូមិភាគពាយ័ព្យ។ លោក **ស្សុត** បានប្រឈមមុខនឹងកំណត់ហេតុស្តីពីកិច្ចប្រជុំទាក់ទងនឹងការងារមូលដ្ឋាននៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះ។ កិច្ចប្រជុំនេះ មានការចូលរួមពី **ប៉ុល ពត, នួន ជា, ខៀវ សំផន,** និង **ខឿន** ហៅ **សឿ វ៉ាស៊ី** ដែលជាប្រធានការិយាល័យគណៈកម្មាធិការមជ្ឈិមបក្សទូទៅ។ ឯកសារបានកត់សម្គាល់ពីរបាយការណ៍ដែលផ្ញើមកពីតំបន់ ៣០៣ តំបន់១០៦ និងតំបន់ ១០៣ ដែលផ្តល់ព័ត៌មានជាក់លាក់អំពីសកម្មភាពរបស់សត្រូវ។ លោក **ស្សុត** បានពន្យល់ថា ការដាក់បញ្ចូលព័ត៌មានលម្អិតស្តីពីលក្ខខណ្ឌទៅលើហេតុផលទាំងអស់ហ្នឹង គឺជារឿងធម្មតានៅក្នុងទូរលេខ ឬក្នុងកំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍។

ការធ្វើកូដទូរលេខ និងនីរសារ ត្រូវបានប្រើជាមធ្យោបាយនៃការទំនាក់ទំនង។ ដើម្បីជៀសវាងការរំខាន នីរសារត្រូវបានប្រើសម្រាប់ជាការបញ្ជាដែលពាក់ព័ន្ធនឹងការបោសសម្អាតមន្ត្រីជាន់ខ្ពស់ និងសារសម្ងាត់ខ្លាំងផ្សេងទៀត ដូចជាការបញ្ជាពីការិយាល័យគណៈអចិន្ត្រៃយ៍បក្សទូទៅរបស់ភូមិភាគបូព៌ា។

## ជ. គោលនយោបាយ និងការអនុវត្តន៍

លោក **ស្សុត** បានបញ្ជាក់ថា ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥ គោលនយោបាយមួយចំនួនបានបង្កើតឡើង ហើយបានបន្តក្លាយជាមូលដ្ឋាននៃគោលនយោបាយសម្រាប់របបកម្ពុជាប្រជាធិបតេយ្យ។ **ប៉ុល ពត** បានធ្វើគោលនយោបាយចំនួនបីជាពិសេស៖ ទី១) ឡោមព័ទ្ធរាជធានីភ្នំពេញប្រកបដោយប្រសិទ្ធភាព ទី២) រឹតបន្តឹងសន្តិសុខនៅជុំវិញភ្នំពេញនិង ទី៣) បង្កើតវិធីសាស្ត្រត្រួតពិនិត្យខ្លាំងបន្ថែមទៀតដូចជាការកសាងពន្ធនាគារ និងការឱ្យទៅរៀនសូត្រឡើងវិញ និងការកាប់សម្លាប់។[11] លោក **ស្សុត** ក៏បានបញ្ជាក់ថាលោក

**ភី ភួន** បានប្រាប់គាត់ថា មានកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចំនួន បីទៅបួនដង នៅក្នុងចន្លោះឆ្នាំ១៩៧៣ ដល់ ឆ្នាំ១៩៧៥។[12] ក្នុងកិច្ចប្រជុំទាំងនេះ ការសម្រេចចិត្តនានាត្រូវបានធ្វើឡើងគឺ បញ្ជូនពួកពាណិជ្ជករចេញ ដើម្បីធានាឱ្យបាននូវការត្រួតត្រាដាច់ខាតរបស់បក្សកុម្មុយនីស្តកម្ពុជាលើការចែកចាយផ្គត់ផ្គង់ទំនិញ និងការរារាំងពួកមូលធននិយម ក៏ដូចជាការជម្លៀសប្រជាជនចេញពីភ្នំពេញ និងចេញពីទីក្រុងខេត្តដទៃៗទៀត ហើយក៏ដើម្បីសម្លាប់កម្មាភិបាលដែលមានឈ្មោះថា ប្រសិទ្ធិ --- ហើយនេះជាលើកដំបូងដែលគណៈអចិន្ត្រៃយ៍ បានអនុញ្ញាតឱ្យសម្លាប់សមាជិករបស់ខ្លួនម្នាក់។[13]

លោក **ស្បេត** បានសង្កត់ធ្ងន់ថា គោលបំណងទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជា គឺជាចេតនាល្អ ដែលចេតនានេះ គឺគ្មានន័យអ្វីទាំងអស់ ដោយមិនគិតពិចារណា ឬខ្វល់ពីការឈឺចាប់ ដែលបក្សកុម្មុយនីស្តកម្ពុជាបានបង្កឱ្យឡើង ដើម្បីសម្រេចឱ្យបាននូវគោលដៅបដិវត្តន៍។ លោកក៏បានបញ្ជាក់ទៀតថា ការអនុវត្តន៍គោលនយោបាយក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនេះ គឺមិនដូចគ្នាទាំងអស់នោះទេ ដោយមានភាពខុសប្លែកគ្នាពីភូមិភាគមួយទៅភូមិភាគមួយទៀត ហើយខុសគ្នាសូម្បីតែពីកម្មាភិបាលខ្មែរក្រហមដែលទទួលបន្ទុកពីកន្លែងមួយទៅកាន់មួយផ្សេងទៀត។

## ឈ. សមូហភាព សហករណ៍ និងការបំបាត់ក្រដាសប្រាក់

អ្នកជំនាញ បានផ្តល់យោបល់ថា មូលហេតុសំខាន់សម្រាប់ការធ្វើសមូហភាព គឺជាមនោគមវិជ្ជាពោលគឺ កម្មសិទ្ធិសហគមន៍លុបបំបាត់លើកម្មសិទ្ធិឯកជន កុម្មុយនីស្តប្រឆាំងទៅនឹងមូលធននិយម។ បក្សកុម្មុយនីស្តកម្ពុជា ចង់សម្រេចឱ្យបាននូវសមភាពសម្រាប់ពលរដ្ឋរបស់ខ្លួន ដែលត្រូវបានបង្ហាញតាមរយៈការលុបបំបាត់ភាពខុសគ្នាទាំងអស់នៅក្នុងជីវភាពរស់នៅ និងទ្រព្យសម្បត្តិ។ លោក **ស្បេត** បានឯកភាពថា ការធ្វើសមូហភាព និងការបង្កើតសហករណ៍ ត្រូវបានអភិវឌ្ឍឡើងចាប់តាំងពីឆ្នាំ១៩៧៤ ដោយមានគោលបំណងជាក់ស្តែងដើម្បីគ្រប់គ្រងការផ្គត់ផ្គង់ស្រូវ និងទប់ស្កាត់ការអន្តរាគមន៍របស់វៀតណាម។ អ្នកជំនាញបានរម្លឹកថា ការធ្វើសមូហភាព និងការជម្លៀសប្រជាជន មិនគួរមានភាពយល់ច្រឡំ ដោយសារតែការធ្វើសមូហភាព អាចធ្វើទៅកើតដោយមិនចាំបាច់មានការជម្លៀសប្រជាជន។ ខណៈពេលដែលសហករណ៍ជាច្រើន ត្រូវបានបង្កើតឡើងឱ្យមានរួចរាល់ហើយក្នុងភូមិ អ្នកភូមិមួយចំនួនមកពីជុំវិញព្រំដែនប្រទេសវៀតណាម និងកម្ពុជា ត្រូវបានគេផ្លាស់ទីទៅកាន់តំបន់ផ្សេងទៀតដើម្បីបង្កើតសហករណ៍នៅទីនោះ។

ការប្រែប្រួលទាំងស្រុងទៅរកលទ្ធិកុម្មុយនីស្តដ៏ឆាប់រហ័សនេះ ត្រូវបានធ្វើឡើង ដោយគ្មានការសម្របសម្រួល ក្នុងការបង្កើតសង្គមមួយដែល "គ្មានទ្រព្យសម្បត្តិ"។ លោក **ស្បេត** បានផ្តល់យោបល់ថា **ប៉ុល ពត** និងបក្សកុម្មុយនីស្តកម្ពុជា បានច្រានភាពសមហេតុផលនៃលទ្ធិកុម្មុយនីស្ត ឈានដល់ភាពជ្រុលនិយមហួសហេតុដោយគ្មានពិចារណាពីការពិតជាក់ស្តែង ហើយនេះគឺជាលទ្ធផល "មហន្តរាយដ៏គួរឱ្យភ័យខ្លាច"។ លោក **ស្បេត** បានប្រៀបធៀបរបបកុម្មុយនីស្តកម្ពុជានេះ ផ្ទុយស្រឡះទៅនឹងរបបកុម្មុយនីស្តរបស់ប្រទេសចិន ដែលលោក **ម៉ៅ សេទុង** បានទុកឱ្យមានចន្លោះពេលអន្តរកាលនៃលទ្ធិកុម្មុយនីស្ត ក្នុងរយៈពេលពីប្រាំទៅប្រាំមួយឆ្នាំមុនពេលការផ្លាស់ប្តូររបបនេះឲ្យអនុវត្តន៍។ ការផ្លាស់ប្តូរបន្តិចម្តងៗបែបនេះ គឺមិនមាននៅក្នុងរបៀបវារៈ

របស់បក្សកុម្មុយនីស្តកម្ពុជានោះទេ។ លោក **ស្បេត** បានថ្លែងថា សូម្បីតែមុនពេលការដួលរលំទីក្រុងភ្នំពេញ ការផ្លាស់ប្តូរទៅរកសង្គមមួយដែលគ្មានទ្រព្យសម្បត្តិឯកជន គឺមានរួចទៅហើយនៅក្នុងភូមិភាគរំដោះមួយចំនួន ដែលការប្រើប្រាស់រូបិយប័ណ្ណក្នុងរបប **លន់ នល់** ត្រូវបានផ្អាកឈប់ប្រើរួចទៅហើយ។ ការបំបាត់ក្រដាសប្រាក់នេះមិនមែន ជាផលវិបាកនៃលទ្ធិកុម្មុយនីស្តដោយស្វ័យប្រវត្តិនោះទេ។ របបកុម្មុយនីស្តផ្សេងៗទៀត សូម្បីតែប្រទេសចិន នៅក្នុងពេលជំហានមហាលោតផ្លោះ គឺនៅតែត្រូវប្រើរូបិយប័ណ្ណ។ គាត់បាននិយាយថា ការលុបបំបាត់ក្រដាសប្រាក់របស់ខ្មែរក្រហម បានផ្អែកលើការជឿជាក់ថា ទ្រព្យសម្បត្តិឯកជននឹងនាំឱ្យមានវិសមភាព។

## ៣. ការជម្លៀសប្រជាជន

"សៀវភៅប្រវត្តិសាស្ត្រ" របស់លោក **ស្បេត** បានបង្ហាញពីសារៈសំខាន់នៃការជម្លៀសប្រជាជនចេញដូចជានៅក្នុងខេត្តក្រចេះ និងស្រុកឧត្តុង្គ ដែលលិទ្ធផលចេញពីការសម្រេចចិត្ត បានធ្វើឡើងនៅក្នុងឆ្នាំ ១៩៧៣ (សូមមើល ផ្នែកទី២. ខ)។[14] លោក **ស្បេត** បានរៀបរាប់ថា **ភី ភួន** ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សដទៃទៀតរបស់គាត់ បានប្រាប់គាត់ថាការជម្លៀសចេញឧត្តុង្គនេះគឺ "សំខាន់ជាពិសេស" ពីព្រោះវាគឺជាការសាកល្បង ថាតើប្រជាជននៅតាមទីក្រុងអាចត្រូវបានផ្លាស់ទីទាំងហ្វូងទៅកាន់សហករណ៍បានដែរឬយ៉ាងណា? ទោះជាយ៉ាងណាក៏ដោយ ការជម្លៀសប្រជាជនដំបូងឡើយ ក៏ត្រូវបានជំរុញកាន់តែខ្លាំងឡើងៗក្រោមហេតុផលជាក់ស្តែង គឺអះអាងថាដើម្បីគ្រប់គ្រងប្រជាជន។ គាត់បានញែកឱ្យឃើញភាពខុសគ្នាពីខាងជម្លៀសមុន និងក្រោយខែមេសា ឆ្នាំ១៩៧៥ ដូចជា ការជម្លៀសចេញពីភ្នំពេញ និងខេត្តបាត់ដំបង ដែលការជម្លៀសនេះ មានគោលបំណងដើម្បីជម្លៀសឲ្យអស់ចេញពីទីក្រុង។ ការជម្លៀសប្រជាជនចេញពីទីប្រជុំជន គឺដើម្បីលុបបំបាត់អំពើពុករលួយដែលប្រមូលផ្តុំនៅទីក្រុង ខណៈដែលនៅទីជនបទ ត្រូវបានគេមើលឃើញថាជាកន្លែង "ដ៏បរិសុទ្ធ" (មិនមានអំពើពុករលួយ)។

ជាពិសេស ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ លោក **ស្បេត** បានផ្តល់ចម្លើយថា ចំនួនប្រជាជននៅទីក្រុងភ្នំពេញមុនពេលដួលរលំនៃរបបនេះធ្លាក់ចូលទៅក្នុងសម័យខ្មែរក្រហម មាចំនួន៣.០០០.០០០ នាក់។ អ្នកជំនាញបានប៉ាន់ប្រមាណថា អ្នករស់នៅទីក្រុងមានតែប្រមាណ ៦០០.០០០ នាក់ នោះទេ ខណៈដែលអ្នកផ្សេងៗទៀត គឺជាអ្នកដំណើរចេញចូលភ្នំពេញដែលមកពីជនបទ ដែលពួកគេបានរត់គេចពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ឬសង្គ្រាមស៊ីវិល។ លោកបានលើកឡើងថា ការព្យាករណ៍ដែលមិនច្បាស់លាស់របស់គាត់នៅក្នុង "សៀវភៅប្រវត្តិសាស្ត្រ" ដែលបានលើកឡើងថា ប្រជាជនចំនួន ២០.០០០ នាក់ ដែលបានស្លាប់ក្នុងអំឡុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញ គឺ "មិនអាចបង្ហាញជាភស្តុតាង" បាននោះទេ ខណៈវាគឺជាតួលេខកណ្តាលដកចេញពីការព្យាករណ៍ខុសៗគ្នានៃប្រភពផ្សេងៗទៀត។

*លោក **ស្បេត** បានច្រានចោលយុត្តិកម្ម ដែលបានដកស្រង់ជាញឹកញាប់ទៅលើការជម្លៀសប្រជាជន ចេញពីទីក្រុងភ្នំពេញថា ការជម្លៀស គឺជាការព្យាយាមជៀសវាងពីគ្រោះទុរ្ភិក្ស។ លោកបានពន្យល់ថា មុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ អ្នករស់នៅទីក្រុងភ្នំពេញបានទទួលការផ្គត់ផ្គង់ម្ហូបអាហាររបស់ពួកគេតាមរយៈ ជំនួយមនុស្សធម៌។ នៅថ្ងៃដែលទីក្រុងដួលរលំ មានការបម្រុងអាហារទុកមួយចំនួនសម្រាប់រយៈពេលពីរបីថ្ងៃ។*

*"ប្រជាជនដែលនៅនឹងមួយកន្លែងបែបហ្នឹង គឺមានភាពកាន់តែងាយស្រួលដើម្បីផ្គត់ផ្គង់អាហារជាងមនុស្សរាប់លាននាក់ដែលកំពុងតែចាកចេញទាំងហ្វូងពីទីក្រុងនៅគ្រប់ច្រកល្ហក"។*[15]

នេះបើយោងតាម "ការពិចារណាពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាពីដំណាក់កាលដំបូងរហូតដល់អំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ" របស់លោក **ខៀវ សំផន** (តទៅហៅថា"ការពិចារណា") ថា **ប៉ុល ពត** បានថ្លែងថា ការទប់ស្កាត់ការបះបោរ គឺជាហេតុផលមួយសម្រាប់ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ លោក **ស្សូត** បានផ្តល់សក្ខីកម្មថា នេះជាការពិត ដែលជាមូលហេតុចម្បងមួយសម្រាប់ធ្វើការជម្លៀសប្រជាជនពីទីក្រុង។ លោក **ស្សូត** បានអះអាងថា នៅពេលដែលអ្នកទីក្រុងត្រូវបានគេផ្លាស់ទីលំនៅទៅនៅតាមទីជនបទ បណ្តាញទំនាក់ទំនងរបស់ពួកគេនឹងត្រូវបានបំផ្លាញចោល ហើយមានភាពងាយស្រួលសម្រាប់ត្រួតត្រាពួកគេ ហើយនិងប្រហែលជាមិនមានការបះបោរ។

មានការជម្លៀសបន្ថែមទៀត នៅចុងឆ្នាំងឆ្នាំ១៩៧៥ លោក **អាប់ឌុលហាក់** បានពិនិត្យថា លោក **ស្សូត** បានផ្អែកលើឯកសារដែលមានចំណងជើងថា "កំណត់ត្រានៃដំណើរទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍ទៅកាន់ភូមិភាគពាយ័ព្យ" ដែលបានរៀបរាប់អំពីតម្រូវការកម្មករបន្ថែមចំនួន៤០០.០០០នាក់ នៅក្នុងភូមិភាគនេះ។ លោក **ស្សូត** បានបញ្ជាក់ថា នេះគឺពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនដែលបានពណ៌នានៅក្នុងសៀវភៅរបស់គាត់ នៅពេលដែល **ប៉ុល ពត** បានសម្រេចចិត្តចែកចាយកម្លាំងពលកម្មជាថ្មី ដើម្បីបំពេញសេចក្តីតម្រូវការរបស់តំបន់ផ្សេងគ្នា ដោយបង្ខំប្រជាជនផ្លាស់ទីម្តងទៀតនៅមុនពេលរដូវប្រមូលផល។[16] លោក **ស្សូត** បានអះអាងថា ការអនុវត្តន៍ចំពោះការជម្លៀសប្រជាជន គឺផ្អែកទៅលើគំនិតថា "ចុងបញ្ចប់ផ្តល់យុត្តិកម្មទៅលើវិធីសាស្ត្រ" ហើយប្រជាជនត្រូវបានគេចាត់ទុកថា ត្រូវហ៊ានលះបង់ដោយដឹងពីគោលបំណងក្នុងការឈានសម្រេចឱ្យបាននូវប្រទេសកម្ពុជាមួយដែលរឹងមាំ និងរុងរឿង។

## ដ. ខ្នាំង ការបោសសម្អាតផ្ទៃក្នុង និងការប្រព្រឹត្តិចំពោះក្រុមគោលដៅ

លោក **អាប់ឌុលហាក់** បានដកស្រង់មេរៀងមួយចេញពី "សៀវភៅប្រវត្តិសាស្ត្រ" ដែល **ប៉ុល ពត** បានលើកឡើពីជោគវាសនានៃបក្សកុម្មុយនីស្តឥណ្ឌូនេស៊ី ត្រង់ចំណុចថា ពួកកុម្មុយនីស្តទាំងអស់នោះមិនពឹងផ្អែកលើពួកគហបតីនេះទេ។ ទាំងនេះបាននាំទៅរកការកែប្រែគោលនយោបាយ សំដៅទៅរកអ្នកគាំទ្រដែលមិនមែនជាសមាជិក។ ចលនាកែប្រែនេះ បានចាប់ផ្តើមអនុម័តយកកាន់តែខ្លាំងឡើងនូវឥរិយាបថចាត់ថ្នាក់ថា "អ្នករាល់គ្នាដែលមិននៅខាងយើង គឺជាពួកដែលប្រឆាំងនឹងយើង។"[17] លោក **ស្សូត** បានកត់សម្គាល់ថា បន្ទាប់ពីការបះបោរនៅសំឡូត ការចាប់ផ្តើមការអនុវត្តន៍នេះ គឺនៅខេត្តរតនៈគីរី។ ខណៈពេលដែលទាហានជាអ្នកស្រុក ត្រូវបានដោះលែង ប៉ុន្តែអ្នកដែលមិនវិញ ត្រូវបានគេដឹងថា ត្រូវបានសម្លាប់។ ទោះបីជាមិនមានការណែនាំជាលាយលក្ខណ៍អក្សរ ដើម្បីប្រព្រឹត្តចំពោះសត្រូវតាមវិធីនេះក៏ដោយ ក៏ពួកកម្មាភិបាលបានដឹងថា នេះជាអ្វីដែលបក្សកុម្មុយនីស្តចង់ឱ្យពួកគេធ្វើ។ លោក **ស្សូត** មិនបានរកឃើញភស្តុតាងទូទៅថា ថ្នាក់ដឹកនាំបានអនុវត្តលើកលែងបែបនេះទេ លើកលែងតែក្នុងករណីលោក **ហ្វ្រង់ស័រ ប៊ីស៊ុត** (Mr. François Bizot) ដែលត្រូវបានដោះលែងដោយសារអនុសាសន៍របស់ **ឌុច** និងដោយការសម្រេចចិត្តរបស់**ប៉ុល ពត**។[18]

នេះបើយោងទៅតាម "សៀវភៅប្រវត្តិសាស្ត្រ" មនុស្សគ្រប់រូបដោយមិនគិតពីសាវតារ អាចត្រូវបានជ្រើសរើសឱ្យចូលជាកងទ័ព ឬចូលទៅរណសិរ្សរួបរួមជាតិកម្ពុជា ប៉ុន្តែនៅដើមខែធ្នូ ឆ្នាំ១៩៧០ ភាពជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា បានត្រូវកម្រិតចំពោះអ្នកដែលមានសាវតារជាកសិករក្រីក្រតិចតួច។ សិស្សនិស្សិត និង "ពួកកសិករកម្រិតកណ្តាល" អាចចូលបានតែសម្ព័ន្ធយុវជនប៉ុណ្ណោះ។ លោក **ស្សេត** បានបញ្ជាក់ថា នេះគឺជាការចាំបាច់ដោយសារតែការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ចាំបាច់ធានាថា ពួកឥស្សរជននៃបក្សកុម្មុយនីស្ត នឹងមិនអាចប្រព្រឹត្តអំពើពុករលួយបាន ដោយសារតែកត្តាពីខាងក្រៅ ដូចជាពួកវៀតកុង ដែលចាក់ឫសរឹងមាំនៅក្នុងប្រទេសកម្ពុជានាពេលនោះ។ ពួកបញ្ញវន្តដែលវិវឌ្ឍន៍ខ្លួននៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ដូចជា **ហ៊ូ យុន** និង **ហ៊ូ នឹម** ក៏ត្រូវបានគេបានបំបែកនៅការិយាល័យសន្តិសុខ ស-៣១។ លោក **ស្សេត** បានកត់សម្គាល់ពីសារៈសំខាន់នៃការសម្រេចចិត្តនៅការប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជា នៅឆ្នាំ១៩៧១ ដែលគ្មានសមាជិកជាន់ខ្ពស់ (អ្នកដែលស្វែងរកដើម្បីក្លាយជាបក្សប្រឆាំងស្របច្បាប់ក្នុងអំឡុងរបប**សម្តេចព្រះសីហនុ**) ហើយក៏មិនមែនពួកអ្នកត្រឡប់មកពីទីក្រុងហាណូយ (ខ្មែរដែលបានទៅប្រទេសវៀតណាមបន្ទាប់ពីសង្គ្រាមប្រឆាំងនឹងបារាំងបានបញ្ចប់នៅឆ្នាំ១៩៥៤ ហើយបានក្លាយជាផ្នែកមួយនៃចលនាបក្សកុម្មុយនីស្តដែលមានសម្ព័ន្ធភាពជាមួយវៀតណាម) ត្រូវបានជ្រើសរើសឲ្យជាគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តនេះ។ ក្រុមទាំងពីរខាងលើ មិនត្រូវបានគេជឿទុកចិត្តនោះទេ ដោយសារក្រុមមកពីទីក្រុងហាណូយត្រូវបានគេចាត់ទុកថា ជាពួក "កន្ទក់" ដោយពួកវៀតណាម រីឯក្រុមគណបក្សប្រជាជនវិញ ពួកគេបានយកវិធីសាស្ត្រខុសពីអ្វីដែលត្រូវបានចែងក្នុងចំណុចស្នូលរបស់បក្សកុម្មុយនីស្តកម្ពុជា។ ក្នុងឆ្នាំ១៩៧៣ ខណៈដែលពួកខ្មែរក្រហម ជិតទទួលបានជ័យជម្នះ ពួកវាបានរឹតបន្តឹងការគ្រប់គ្រង និងបានធ្វើការសម្រេចប្រមូលផ្តុំពួកអ្នកមកពីហាណូយ លើកលែងតែអ្នកមួយចំនួនតូច ដែលត្រូវបានគេចាត់ទុកថាជាអ្នកស្មោះត្រង់ ហើយបានដាក់ឱ្យពួកគេឲ្យស្ថិតនៅក្រោមការចាប់ខ្លួន ដោយសារតែមានការសង្ស័យថា ជាភ្នាក់ងារជនជាតិវៀតណាម។ ក្រោយមក ពួកទាំងនេះត្រូវបានសម្លាប់។

លោក **ស្សេត** បានរៀបរាប់ពីការសម្រេចចិត្តនៅមុនឆ្នាំ១៩៧៥ ដើម្បីសម្លាប់សមមិត្តឈ្មោះ **ប្រសិទ្ធិ** ដែលជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តដែលមកពីភូមិភាគនិរតីថាជា "ចំណុចស្លាប់រស់"។ ការសម្រេចចិត្តបែបនេះ បានចាប់ផ្តើមបោសសម្អាតផ្ទៃក្នុង ដែលក្រោយមក "បានបំផ្លាញបក្សកុម្មុយនីស្តកម្ពុជា"។ វាគឺជាការសម្រេចចិត្តដែលគាត់យល់ថា ស្របជាមួយនឹងការសម្រេចចិត្ត ដែលធ្វើឡើងដោយបក្សកុម្មុយនីស្តចិននៅឆ្នាំ១៩៣០ នៅពេលដែលមេដឹកនាំ បានអនុវត្តតាមគោលនយោបាយដែលខុសគ្នាពីថ្នាក់ដឹកនាំត្រូវបានគេចាត់ថាជា "ការប្រឆាំងនឹងបដិវត្តន៍" ហើយនិងត្រូវបានសម្លាប់ចោល។ លោក **ស្សេត** បាននិយាយថា ក្នុងករណីទាំងពីរខាងលើនេះ បក្សកុម្មុយនីស្តដែលស្ថិតនៅក្រោមសម្ពាធដ៏ធំមួយ ហើយមានពួកកម្មាភិបាលដែលមានបទពិសោធតិចតួចប៉ុណ្ណោះបានប្រតិកម្ម ដោយការចាប់ផ្តើមសម្លាប់សមាជិករបស់ខ្លួននៅពេលដែលស្ថិតក្រោមស្ថានភាពដែលមានសម្ពាធ។[19]

លោក **ស្សេត** ក៏បានផ្តល់សក្ខីកម្មផងដែរអំពីមន្ទីរសន្តិសុខ ស-២១ ដែលគាត់បានពិពណ៌នានៅក្នុង "សៀវភៅប្រវត្តិសាស្ត្រ" របស់គាត់ថាជា "ទីកន្លែងដែលមានអំណាចខ្ពស់បំផុត" របស់រដ្ឋសម្រាប់ប្រើអំណាចផ្តាច់ការរបស់ **ប៉ុល ពត**។ លោក **ស្សេត** បានរៀបរាប់ថា បក្សកុម្មុយនីស្តកម្ពុជា គឺជាអង្គភាពដែលបានផ្តល់

សិទ្ធិសេរីភាពស្មើគ្នារបស់បុគ្គលម្នាក់ៗ ដូចច្នេះ ហើយត្រូវតែមានការបង្ក្រាប។ មន្ទីរសន្តិសុខស-២១ គឺជាកន្លែងដែលសិទ្ធិសេរីភាពទាំងអស់ត្រូវបានដកហូតរួមមានដូចជា សិទ្ធិរស់រានមានជីវិត។ លោក **ស្សូត** បានរៀបរាប់បន្ថែមទៀតថា មន្ទីរសន្តិសុខ ស-២១ គឺជាកន្លែងដែលបានរៀបចំឡើងសម្រាប់អ្នកទទួលខុសត្រូវនៅក្នុងរបបនោះ នឹងត្រូវបានយកមកសួរចម្លើយ។ លោក **ស្សូត** បានថា មន្ទីរសន្តិសុខមិនមែនមានតែមួយគត់នោះទេ ហើយមានដូចគ្នាទៅនឹងពន្ធនាគារបារាំងនៅក្នុងប្រទេសអាល់ហ្សេរី។ លោក **ស្សូត** ជឿថា អ្វីដែលធ្វើឱ្យមន្ទីរសន្តិសុខ ស-២១ មិនខុសគ្នាពីមន្ទីរសន្តិសុខក្នុងប្រទេសផ្សេងៗទៀត គឺថាប្រទេសទាំងនោះមានប្រព័ន្ធតុលាការ ហើយមន្ទីរសន្តិសុខបែបនេះ នឹងក្លាយជាផ្នែកមួយដែលកាន់តែសម្ងាត់នៃរបបនេះបន្ថែមទៀត។ នៅកម្ពុជា មន្ទីរ ស-២១ គឺជា "ទីកន្លែងដែលមានអំណាចខ្ពស់បំផុត" ជំនួសឱ្យប្រព័ន្ធនៅក្នុងប្រទេសទាំងមូល ដែលគ្មានទេប្រព័ន្ធតុលាការ។ មន្ទីរសន្តិសុខ ជាជាង "បញ្ហាមួយតែម្ខាង" គឺជាផ្នែកសំខាន់នៃរចនាសម្ព័ន្ធ ដែលខ្សែរយៈបណ្តាញបញ្ជាធ្លាក់ចុះចេញពីមន្ទីរស-២១។

ពាក់ព័ន្ធនឹងការប្រើប្រាស់ចម្លើយសារភាព ដែលយកមកពីអ្នកទោសនោះ លោក **ស្សូត** បានអះអាងថា ចម្លើយទាំងនោះ បានយកមកប្រើប្រាស់ជាយុត្តិកម្មជាច្រើនដង ដែលបានធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជា។ មានការបង្ហាញថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្ទាល់ បានសង្ស័យភាពត្រឹមត្រូវនៃព័ត៌មាននៅក្នុងចម្លើយសារភាព។ លោកបានសំដៅទៅលើ វិធាននៅក្នុងក្រសួងការបរទេសថា មនុស្សម្នាក់អាចត្រូវបានចាប់ខ្លួនប្រសិនបើបានរកឃើញថា គាត់មានការជាប់ពាក់ព័ន្ធបីដងនៅក្នុងការឆ្លើយសារភាព។ ប៉ុន្តែក្រោយមកទៀត ចំនួនដែលពាក់ព័ន្ធក្នុងចម្លើយសារភាព បានកើនឡើងដល់ប្រាំដង។

ទាក់ទងទៅនឹងអត្ថបទខ្លីៗ អំពីបញ្ហាកើតឡើងនៅក្នុងខែកក្កដា ឆ្នាំ១៩៧៣ ចំពោះ "ទង់បដិវត្តន៍"[20] ស្តីពីគោលនយោបាយធ្វើឱ្យប្រជាជនស្ងប់ចិត្ត និងហាមឃាត់ការសម្លាប់គិញនៅចំពោះមុខប្រជាជន លោក **ស្សូត** បានពន្យល់ថា នៅពេលដែលការសម្លាប់ពួកអ្នកប្រឆាំងបដិវត្តន៍នេះ អាចធ្វើបាន ប្រសិនជាការសម្លាប់នេះ ត្រូវបានឡើងក្នុងវិធីមួយដែល "មិនប៉ះពាល់ដល់គោលដៅបដិវត្តន៍"។[21] បញ្ហានេះបាននាំឱ្យមានមនុស្សបាត់ខ្លួន ហើយត្រូវបាននាំខ្លួន ឬចាប់ខ្លួនយកទៅ ហើយមិនដែលឃើញពួកគេត្រឡប់មកវិញ។ លោក **ស្សូត** ក៏បានពន្យល់ផងដែរថា ចំពោះការសន្មតថា កម្មករជំនាញដែលត្រូវបានគេនាំយកដើម្បីសម្លាប់ គឺមិនសំខាន់ថា ត្រឹមត្រូវនោះទេ។ ពួកគេភាគច្រើន បាននាំយកទៅទីក្រុងភ្នំពេញ និងយកទៅធ្វើការងារនៅកន្លែងផលិតកម្ម។

ដោយអ្នកជំនាញដឹងមិនសូវច្បាស់ពីទួលពោធិ៍ជ្រៃ ដែលជាទីកន្លែងសម្លាប់មនុស្ស គាត់បានបញ្ជាក់ថា អតីតមន្ត្រីស៊ីវិល និងមន្ត្រីយោធាជាន់ខ្ពស់ **លន់ នល់** ត្រូវបានសម្លាប់នៅ "កន្លែងខុសៗ និងនៅដំណាក់កាលផ្សេងៗគ្នាក្នុងពេលជម្លៀសប្រជាជន (ចេញពីទីក្រុងភ្នំពេញ)"[22] ក៏ដូចជានៅក្នុងទីក្រុងផងដែរ។ យ៉ាងណាមិញ មានមនុស្សមួយចំនួននៅរស់រានមានជីវិតដោយសារតែមានការអនុវត្តន៍មធ្យោបាយផ្សេងៗគ្នានៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ យោងតាមលោក **ស្សូត** បានឱ្យដឹងថាគណៈអចិន្ត្រៃយ៍បានសម្រេច និងចេញសេចក្តីប្រកាសផ្លូវការតាមរយៈសមាជជាតិដើម្បីសម្លាប់ "ជនក្បត់ប្រាំពីរនាក់" ដែលត្រូវបានគេចាត់ទុកថា ជាក្រុមមេដឹកនាំរដ្ឋប្រហារឆ្នាំ១៩៧០ ប្រឆាំងនឹង**សម្តេចសីហនុ**។ លោក **ស្សូត** បានផ្តល់យោបល់ថា ទោះបីជាមានការធានាអះអាងថាមានតែជនក្បត់ប្រាំពីរនាក់ទេ ត្រូវបានសម្លាប់ តែក្រោយមកបុគ្គលផ្សេងៗ

ត្រូវបានសម្លាប់បន្ថែមទៀត។ លោក **កូប៉េ** បានសួរទៅកាន់លោក **ស្បួត** ថាតើមានការយល់ច្រឡំលើគោលនយោបាយទាក់ទងនឹងអតីតមន្ត្រី **លន់ នល់** ក្នុងចំណោមពួកកម្មាភិបាលថ្នាក់ទាប និងថ្នាក់កណ្តាលឬទេ? លោក **ស្បួត** បានឆ្លើយតបថា មានសារពីរសម្រាប់ឱ្យអ្នកស្តាប់ផ្សេងៗគ្នា ព្រោះតែខ្មែរក្រហមមិនបានស្តាប់ស្ថានីយវិទ្យុរបស់រណសិរ្សបង្រួបបង្រួមជាតិកម្ពុជាទេ ប៉ុន្តែបែបជាស្តាប់មេរបស់ពួកគេ នៅពេលដែលមានការប្រកាសជាសាធារណៈអំពីជនក្បត់ទាំងប្រាំពីរនាក់ មានចេតនាចង់ឱ្យអ្នករស់នៅទីក្រុងភ្នំពេញដឹងឮ។

លោក **ស្បួត** បានអះអាងថា ការសម្លាប់ទាហាន និងមន្ត្រី **លន់ នល់** បានបង្កើតឡើងទុកជាគំរូសម្រាប់ទូទាំងប្រទេស។ លោកបានដកស្រង់កិច្ចសម្ភាសន៍របស់លោកជាមួយ **ភី ភួន** ដែលបានចូលរួមនៅក្នុងការប្រយុទ្ធនៅខេត្តរតនៈគីរីក្នុងឆ្នាំ១៩៦៨ និងបានពន្យល់ទៅកាន់អ្នកជំនាញថា គោលនយោបាយប្រឆាំងនឹងខ្មាំង គឺត្រូវបានគេយល់ជាទូទៅ។ លោក **កូប៉េ** បានសួរថា តើវាអាចធ្វើទៅកើតទេដែលថាការសម្លាប់ទាហាន **លន់ នល់** ត្រូវបានចាត់ទុកថាជាទង្វើនៃការសងសឹក។ លោក **ស្បួត** បានផ្តល់សក្ខីកម្មថានៅពេលដែលកងកម្លាំង **លន់ នល់** បានចូលទៅដល់ខេត្តរតនៈគិរី ពួកគេបានកាត់ក្បាលពួកកសិករ ដូច្នេះពួកគេអាចកាត់ក្បាល ពួកកសិករ និងបានទទួលរង្វាន់ជាទឹកប្រាក់។ បន្ទាប់មក **លន់ នល់** បានកែតម្រូវបទបញ្ជា ហេតុដូចនេះហើយ ក្បាលទាហានខ្មែរក្រហមដែលទើបស្លាប់ ត្រូវយកកាំភ្លើងមកជាមួយផងដើម្បីធានាថា សាកសពដែលទើបនឹងស្លាប់ទៅហើយនោះគឺជាទាហាន។ អ្នកជំនាញបានថ្លែងថា "វាអាចជារឿងចម្លែក" "ប្រសិនបើរឿងស្រដៀង គ្នានេះមិនត្រូវបានធ្វើដោយទាហានខ្មែរក្រហមជាបុគ្គល ឬក្រុមទាហានតូចណាមួយ"។[23] ទោះជាយ៉ាងណាក៏ដោយ លោកបានចាត់ទុកថាការកើតឡើងទាំងនេះខុសគ្នាពី "អាកប្បកិរិយានៃគំរូនៅទូទាំងប្រទេស"។ អ្នកជំនាញ បានបន្តទៀតថា នៅពេលដែលគ្មានការណែនាំជាលាយលក្ខណ៍អក្សរពីថ្នាក់លើដើម្បីសម្លាប់ទាហាន និងមន្ត្រីជាន់ខ្ពស់ **លន់ នល់** នោះទេ គាត់ប្រាកដថាការសម្លាប់នេះ បានកើតឡើងដោយសារតែគោលនយោបាយ ពីព្រោះវាបានកើតឡើងគ្រប់ទីកន្លែង។

នៅពេលលោក **កូប៉េ** បានជំរុញឱ្យលោក **ស្បួត** បង្ហាញពីការធ្វើសេចក្តីសន្និដ្ឋានថា ការសម្លាប់កើតចេញពីគោលនយោបាយដោយរបៀបណានោះ លោកបានថ្លែងថា ជាការពិត មន្ត្រីនិងទាហាន **លន់ នល់** ដែលនៅមានឋានៈធំមួយចំនួនត្រូវបានសម្លាប់ ហើយគាត់បានធ្វើការវិនិច្ឆ័យដោយផ្អែកលើព័ត៌មានដែលគាត់អាចរកបានតាមរយៈប្រភពទាំងអស់របស់គាត់។ នៅពេលសាកសួរអំពីការដកស្រង់ចេញពីប្រភពរបស់គាត់ ស្តីពីការសម្លាប់ទាហាន និងមន្ត្រី **លន់ នល់** ក្នុងឆ្នាំ១៩៧៤ លោក **ស្បួត** បានដកស្រង់ពីចេញពី **ភី ភួន** "រៀលលីធី ខេមបូឌាន" (Réalité Cambodgiennes) និង សៀវភៅរបស់អ្នកប្រវត្តិសាស្ត្រយោធារបស់សហរដ្ឋអាមេរិក (Wilfred Deac)។ លោក **ស្បួត** ក៏បានសំដៅដល់ការអនុវត្តន៍ត្រង់ចំណុចថា បន្ទាប់ពីទទួលបានសេចក្តីណែនាំនៅក្នុងសមាជ ឬក្នុងកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិមមក មេដឹកនាំតាមភូមិភាគ បានវិលត្រឡប់មកវិញ ហើយអនុវត្តគោលនយោបាយ ដោយផ្អែកលើការបកស្រាយផ្ទាល់ខ្លួនរបស់ពួកគេ។ លោក **ស្បួត** បានកត់សម្គាល់ថា ចំណុចនេះ គឺជាលទ្ធផលដែល "មិនមែនរាល់ទាហាន **លន់ នល់** ឬរាល់មន្ត្រីជាន់ខ្ពស់ ត្រូវបានគេសម្លាប់នោះទេ ប៉ុន្តែ នោះគឺជាលទ្ធផលដែលកើតឡើងជាទូទៅនៅទូទាំងប្រទេសកម្ពុជា"។[24] ដោយសំដៅយ៉ាងជាក់លាក់ទៅលើទួលពោធិ៍ជ្រៃ លោក **កូប៉េ** បានសួរថាតើ លោក **ស្បួត** បានឮពីការប្រើប្រាស់ផែនការសម្ងាត់ដើម្បីទាញទឹកចិត្តមន្ត្រី **លន់ នល់** យកមកសម្លាប់ចោល ពោលគឺ ប្រមូលពួក

គេមកចូលរួមការប្រជុំ ហើយប្រាប់ថា នឹងយកពួកគេទៅជួប**សម្តេច** វិធីសាស្រ្តបែបនេះ ក៏ត្រូវបានយកមកប្រើប្រាស់មិនត្រូវតែនៅខេត្តពោធិ៍សាត់នោះទេ។ លោក **ស្បត** បានថ្លែងថា លោកបានឮរឿងស្រដៀងគ្នានេះដែរនៅក្នុងខេត្តបាត់ដំបង ប៉ុន្តែមិនដែលបានឮពីផែនការសម្ងាត់ដូចគ្នាដែលបានប្រើនៅក្រៅភូមិភាគពាយព្យនោះឡើយ។

លោក **កូប៉េ** ហាក់ដូចជាព្យាយាមស្វែងរកទ្រឹស្តីដែលមេដឹកនាំខ្មែរក្រហមក្នុងតំបន់ បានសម្លាប់ទាហាន **លន់ នល់** ដោយសួរថាតើ **រស់ ញឹម** ជាមេបញ្ជាការភូមិភាគពាយព្យដែលត្រូវបានគេសម្លាប់នៅឆ្នាំ១៩៧៨ បានបញ្ជាឱ្យមានការសម្លាប់នៅក្នុងភូមិភាគពាយព្យ ដោយគ្មានការណែនាំពីគណៈអចិន្ត្រៃយ៍មែនឬទេ? លោក **ស្បត** បានផ្តល់ចម្លើយថា វាជាការលំបាកដើម្បីជឿថា មេបញ្ជាការភូមិភាគធ្វើសកម្មភាព "ប្រឆាំង" ឬធ្វើសកម្មភាព "ក្រៅការសម្រេចគោលនយោបាយរួម" ណាមួយនោះ។ ខណៈដែលអ្នកជំនាញបានយល់ស្របថា មានសេរីភាពដ៏គួរឱ្យកត់សម្គាល់នៅក្នុងភូមិភាគខុសៗគ្នា វាមានការលំបាកសម្រាប់គាត់ដើម្បីជឿថា មេដឹកនាំភូមិភាគបានប្រព្រឹត្តហួសពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទាំងស្រុង។

ទាក់ទងទៅនឹង "ប្រជាជនថ្មី" លោក **ស្បត** បានរៀបរាប់អំពីវិធីដែល **ហ៊ូ យុន** បានព្រមានប្រជាជនក្នុងការជ្រើសរើសយកបដិវត្តន៍ ដោយមានចាក់ផ្សាយនៅឆ្នាំ១៩៧៥ មានន័យថា អ្នកដែលបានរត់ទៅជ្រកនៅក្នុងទីក្រុងភ្នំពេញ ត្រូវបានគេចាត់ទុកថា បានជ្រើសរើសបក្សម្ខាងទៀត។ ការនេះបាននាំទៅរកភាពខុសគ្នារវាង "ប្រជាជនចាស់" ដែលសំដៅដល់អ្នកដែលគាំទ្រខ្មែរក្រហម និង "ប្រជាជនថ្មី" ដែលរួមបញ្ចូលអ្នកដែលត្រូវបានគេមើលឃើញថា គាំទ្រ **លន់ នល់** ដោយ "ការជ្រើសរើសចេញពីចិត្តរបស់ពួកគេ"។ លោក **ស្បត** បានពន្យល់ទៅអ្នកស្រី **ម៉ុច សុវណ្ណារី** មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា ប្រជាជនថ្មីត្រូវបានគេរើសអើងក្នុងអំឡុងពេលពីរឆ្នាំដំបូង។ អំពើប្រព្រឹត្តិទៅលើពួកគេ គឺខុសពីគ្នានេះ ហើយត្រូវបានលុបចោលបន្តិចម្តងៗនៅក្នុងឆ្នាំ១៩៧៨។ លោក **ស្បត** បានអះអាងថា គោលបំណងនៃរបបនេះ គឺមិនដែលសម្លាប់ប្រជាជនថ្មីទេ ប៉ុន្តែ ជាការជម្លៀសពួកគេទៅវិញទេ។

សហព្រះរាជអាជ្ញាអន្តរជាតិ លោក **អ៉ាប់ឌុលហាក់** បានសំដៅទៅលើអត្ថបទនៅក្នុង "សៀវភៅប្រវត្តិសាស្រ្ត" អំពីឋានានុក្រមរវាង "ប្រជាជនចាស់" និង "ប្រជាជនថ្មី" ការប្រើប្រាស់ភាពអត់ឃ្លាន ជាមធ្យោបាយនៃការដាក់ទណ្ឌកម្ម ក៏ដូចជាការសម្លាប់ "ពួកសមាសភាពអាក្រក់"។[25] អ្នកជំនាញបានពន្យល់ថា គោលបំណងបោសសម្អាត "ក្រុមខ្មាំង" ឬ "ពួកនិន្នាការ" បានយកមកធ្វើជាយុត្តិកម្មសម្រាប់ការសម្លាប់អ្នកដែលធ្វើខុសវិន័យនៅក្នុងសហករណ៍ ពីព្រោះវាជាការបង្ហាញពីនិន្នាការបុគ្គលនិយម និងនិន្នាការគហបតី។ នៅពេលដែលប្រព័ន្ធស្តារនីតិសម្បទាចំពោះអ្នកធ្វើខុសវិន័យ មាននៅក្នុងប្រព័ន្ធកុម្មុយនីស្តផ្សេងទៀតដែរ ការដាក់ទណ្ឌកម្មលើការប្រព្រឹត្តិខុស ដូច្នោះ ក្នុងសម័យខ្មែរក្រហមគឺទោសស្លាប់។ ប្រទេសផ្សេងៗទៀត មានដូចជា ប្រទេសចិនបានឱ្យមានការអប់រំឡើងវិញ ដែលអាចឱ្យជនល្មើសពិចារណាខ្លួនឯងម្តងទៀត ហើយបន្ទាប់មក ត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងសហគមន៍។ លោក **ស្បត** បានបញ្ជាក់ថា មានការព្យាយាមធ្វើឡើងដោយកម្ពុជាប្រជាធិបតេយ្យ ដើម្បីអប់រំឡើងវិញទៅលើអ្នកប្រកបវិជ្ជាជីវៈ ដូចជា វេជ្ជបណ្ឌិត មេធាវី គ្រូបង្រៀន និងវិស្វករ ដោយដាក់ពួកគេឱ្យនៅក្នុងស្ថានភាពរស់នៅលំបាក ដែលបានបណ្តាលឱ្យមានការស្លាប់បាត់បង់ជីវិតជាច្រើន។ បន្ទាប់មក អ្នករស់រានមានជីវិត ត្រូវបានគេចាត់ទុកថា មានប្រយោជន៍មួយផ្នែកនៃ

ប្រជាជនថ្មី និងបានរស់នៅទីជនបទ ដើម្បីធ្វើកែប្រែខ្លួនឯងបន្ថែមទៀតតាមរយៈការងារកសិកម្ម។ លោក **សុន សេន** ក៏បានព្យាយាមចាប់ផ្តើមកម្មវិធីអប់រំឡើងវិញផងដែរ ដែលនៅទីបំផុត ត្រូវបានលុបចោលដោយសារតែកម្មវិធីនេះ ត្រូវបានចាត់ទុកថា គ្មានប្រសិទ្ធភាព។

ចំពោះជនជាតិភាគតិចវិញ លោក **ស្សុត** បានជឿជាក់ថា គ្មានការព្យាយាមសម្លាប់ក្រុមជនជាតិភាគតិចមួយណាឲ្យប្រាកដទេណាមួយនោះទេ។ លោក **ស្សុត** បានប្រាប់ថា ពាក់ព័ន្ធទៅនឹងការកំណត់គោលដៅដើម្បីសម្លាប់ចោលជនជាតិភាគតិច និងប្រជាជនក្រោកឡើងប្រឆាំងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានកំណត់ធ្វើឡើង មិនដូចនៅក្នុងប្រទេស រ៉ាវ៉ាន់ដា (Rwanda) ឬបក្សណាស៊ី (Nazi) នៅអាល្លឺម៉ង់នោះទេ។ លោក **ស្សុត** បានដកស្រង់ឧទាហរណ៍ជនជាតិចាម ដែលមានវប្បធម៌ខុសគ្នាពីជនជាតិខ្មែរ ហើយស្ថិតក្រោមសម្ពាធដូចប្រជាជនដទៃទៀតដែរ។ ទោះជាយ៉ាងណាក៏ដោយ លោក **ស្សុត** បានថ្លែងថា បញ្ហានេះគឺមិនស្មើទៅនឹង "ការព្យាយាមដោយចេតនា ដើម្បីសម្លាប់ក្រុមជាតិសាសន៍" នោះទេ។[26]

## ឋ. ក្រុមគ្រួសារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

លោក **ស្សុត** បានពន្យល់ទៅលោក **វ៉េង ហ៊ត់** (សហព្រះរាជអាជ្ញាជាតិ) ថា អង្គការត្រូវបានគេសន្មតថា ជាគ្រួសារពិតប្រាកដនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ មិនគួរមានគ្រួសាររបស់នរណាមួយ ជ្រៀតជ្រែកជាមួយនឹងភាពស្មោះត្រង់របស់បុគ្គលចំពោះអង្គការនោះទេ ហើយអាពាហ៍ពិពាហ៍ជាច្រើន ត្រូវបានធ្វើឡើងសម្រាប់គោលបំណងជាក់ស្តែងដូចជាការបង្កើតកូនចៅ។ លោកក៏បាននិយាយផងដែរថា កុមារត្រូវបានផ្តាច់ចេញពីឪពុកម្តាយ ដើម្បីឱ្យចំណងគ្រួសារកាន់តែដុនដាប និងធានាឱ្យបានអ្នកជំនាន់ក្រោយនៃប្រជាជនកម្ពុជាឱ្យចេះលះបង់ និងពឹងផ្អែកទៅលើរបបខ្មែរក្រហម។ គាត់បានកត់សម្គាល់ឃើញថា មានការប្រព្រឹត្តិផ្សេងគ្នាចំពោះមេដឹកនាំ និងពួកកម្មាភិបាលជាន់ខ្ពស់ ដែលត្រូវបានអនុញ្ញាតឱ្យរស់នៅជាមួយគ្រួសាររបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ អ្នកជំនាញ បានសំដៅទៅលើករណីលោក **អៀង សារី** ថា ទោះបីជាក្រុមគ្រួសាររបស់មេដឹកនាំបក្សកុម្មុយនីស្ត បានរស់នៅភ្នំពេញក៏ដោយ ក៏មេដឹកនាំដែលបានរស់នៅក្នុងក្រុម ក-១ ទាំងនោះ បានទៅជួបក្រុមគ្រួសារតែម្តងគត់ក្នុងមួយសប្តាហ៍។

## ឌ. តួនាទី និងចរិតរបស់ជនជាប់ចោទ

លោក **ហ្វីលីព ស្សុត** បានផ្តល់ចម្លើយស្តីពីតួនាទី និងចរិតរបស់ជនជាប់ចោទពីររូបដោយផ្អែកលើប្រភពរបស់គាត់ក្នុងអំឡុងពេលនៃការសរសេរ "សៀវភៅប្រវត្តិសាស្ត្រ" រួមទាំងកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹងលោក **អៀង សារី** និងលោក **ខៀវ សំផន**។ គាត់មិនបានសម្ភាសលោក **នួន ជា** មិនមែន "ដោយសារខ្វះការព្យាយាមទេ" ប៉ុន្តែដោយសារតែជនជាប់ចោទ បានបដិសេធការផ្តល់ជូនម្តងហើយម្តងទៀត។ ខណៈពេលដែលលោក **ហ្វីលីព ស្សុត** បានរៀបរាប់ពី **នួន ជា** ថាជា "បងធំទីពីរ" បន្ទាប់ពី **ប៉ុល ពត** គាត់បានរៀបរាប់ពីលោក **ខៀវ សំផន** ថា ជាអ្នកគាំទ្រដែលសមគំនិតក្នុងចំណោមហេតុផលផ្សេងៗទៀត ដោយសារតែគំនិតប្រឆាំងរបស់គាត់ទៅនឹងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ។

## ខ.១. លោក នួន ជា

នៅក្នុងសៀវភៅរបស់គាត់លោក **ហ្វីលីព ស្សត** បានរៀបរាប់ពីលោក **នួន ជា** ថាជា "មេដឹកនាំលាក់ខ្លួននៅក្នុងព្រៃ" ដោយសំដៅទៅលើសមត្ថភាពរបស់គាត់ ដោយគេមិនអាចរកគាត់ឃើញនៅភ្នំពេញនៅដើមឆ្នាំទសវត្សន៍ ៦០ សូម្បីតែនៅពេលដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀតបាន គៀសខ្លួនចេញពីភ្នំពេញ ដោយសារតែការគាបសង្កត់ពីពួកអ្នកគាំទ្របក្សកុម្មុយនីស្តរបស់**សម្តេចសីហនុ**។

លោក **ស្សត** បានបញ្ជាក់ថា លោក **នួន ជា** បានក្លាយជាអនុលេខាធិការនៃបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ១៩៦០។ លោកបានក្លាយជាអនុលេខាធិការនៃគណៈអចិន្ត្រៃយ៍នៅក្នុងឆ្នាំ១៩៦៣ ហើយបានកាន់តំណែងនេះពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងគណៈអចិន្ត្រៃយ៍ គឺមានឋានានុក្រម។ នៅពេលដែលលោក **ខៀវ សំផន** ឬសមាជិកផ្សេងទៀត បានរាយការណ៍ទៅគណៈអចិន្ត្រៃយ៍ មានន័យថា ពួកគេកំពុងតែរាយការណ៍ទៅកាន់ **ប៉ុល ពត** និង **នួន ជា** ក្នុងកម្រិតជាក់លាក់មួយ។ លោក **ស្សត** បានផ្តល់ចម្លើយថា លោក **នួន ជា** ក៏ជាសមាជិកម្នាក់របស់គណៈកម្មាធិការសន្តិសុខដែលបានគ្រប់គ្រងមន្ទីរសន្តិសុខ ស-២១។

លោក **ស្សត** បានជឿថា លោក **នួន ជា** ទំនងជាមិនមានតួនាទីក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកកងទ័ពទេមុនទសវត្សន៍៩០។ អ្នកជំនាញក៏ជឿដែរថា លោក **នួន ជា** មិនមែនជាសមាជិកនៃគណៈកម្មាធិការកងទ័ពទេ ពីព្រោះឈ្មោះរបស់គាត់មិនមាននៅក្នុងកំណត់ហេតុប្រជុំគណៈកម្មាធិការកងទ័ពទេ។ នៅពេលដែលសួរថា ហេតុអ្វីបានជាលោក **នួន ជា** បានដឹកនាំក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅ ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៦ ទាក់ទងនឹងបញ្ហាកងទ័ព លោក **ស្សត** បានមានយោបល់ថា វាអាចទៅរួចបានដែរក្នុងអំឡុងពេលនោះ **ប៉ុល ពត** នៅឯបរទេស។ លោកស្រីចៅក្រម **ខាត់រ៉ាយថ៍** បានអានខ្លាំងៗពីសេចក្តីថ្លែងការណ៍របស់លោក **នួន ជា** ក្រោយឆ្នាំ១៩៧៥ ថា អ្នកនយោបាយដូចជាគាត់ "បានទទួលការគោរពតិចតួច" ជាងពួកកងទ័ពដែលជាស្ថាប័នដ៏ខ្លាំងបំផុត។ លោក **ស្សត** បានសន្និដ្ឋានលើសេចក្តីថ្លែងការណ៍ថា "បានប្រាស់ចាកពីការពិតទាំងស្រុង"។ លោក **ស្សត** បាននិយាយថា បក្សកុម្មុយនីស្តនេះ គឺជាអង្គការដ៏ខ្ពស់បំផុត ដែលមានការសម្រេចចុងក្រោយទៅលើរាល់បញ្ហាណាមួយ ហើយកងទ័ពគឺស្ថិតនៅក្រោមការបញ្ជារបស់បក្សកុម្មុយនីស្ត និងបានអនុវត្តសេចក្តីសម្រេចចិត្តរបស់អង្គការ។ អ្នកជំនាញ ក៏បានជឿដែរថា លោក **នួន ជា** បានដើរក្នុងតួនាទីមួយដ៏សំខាន់ក្នុងគោលនយោបាយចំពោះការប្រព្រឹត្តិទៅលើខ្មាំងដែលចាញ់ ដែលបញ្ហាបែបនេះត្រូវបានគេ ចាត់ទុកជារឿងនយោបាយ។

សិទ្ធិអំណាចរបស់ **ប៉ុល ពត** និង **នួន ជា** នៅពេលនោះ ត្រូវបានបញ្ជាក់ដោយឈ្មោះដែលបានដាក់ឱ្យពួកគេ។ អ្នកទាំងពីរ ត្រូវបានគេហៅថា "អ៊ុំ" ឬ"ឪពុកមាធំ"។ **ប៉ុល ពត** គឺ "បងទី១" ខណៈពេលជនជាប់ចោទ **នួន ជា** គឺជា "បងទី២"។ លោក **ស្សត** មិនអាចកំណត់ពីទំហំនៃការទំនាក់ទំនងពិតប្រាកដរវាង **ប៉ុល ពត** និង **នួន ជា** ប៉ុន្តែគាត់បានជឿថា ជនជាប់ចោទនេះគឺ "បងធំទី២" បន្ទាប់ពី **ប៉ុល ពត**។ គាត់បានស្មានរឿងនេះចេញពីកិច្ចសម្ភាសរបស់គាត់ជាមួយនឹងពួកកម្មាភិបាលថ្នាក់កណ្តាល ដែលមានទំនាក់ទំនងជាមួយ

អ្នកទាំងពីរ។ ផ្ទុយទៅវិញ លោក **ស្បូត** មិនបានគិតថា **នួន ជា** ធ្លាប់បានជំនួស **ប៉ុល ពត** បណ្តោះអាសន្នធ្វើជានាយករដ្ឋមន្ត្រីស្តីទីនៅពេលណាមួយអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។

នៅពេលដែលលោក **កូប៉េ** សួរថា ហេតុអ្វីវៀតណាម បានដាក់ឈ្មោះសវនាការនៅឆ្នាំ១៩៧៩ ប្រឆាំងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាថាជា "បក្សពួក **ប៉ុល ពត - អៀង សារី**" លោក **ស្បូត** បាននិយាយថា វៀតណាមបានជឿខុសថា **នួន ជា** មានទំនាក់ទំនងមិត្តភាពជាមួយពួកគេ ដោយសារតែគាត់បានទៅប្រទេសវៀតណាម ដើម្បីសិក្សាពីលទ្ធិកុម្មុយនីស្តក្នុងដើមទសវត្សន៍ឆ្នាំ១៩៥០។ វៀតណាមបានដឹងថា លោក **នួន ជា** មិនមែនជា "កូនចៅរបស់ពួកគេ" គឺនៅក្រោយឆ្នាំ១៩៧៩ តែប៉ុណ្ណោះ។ ការនេះបានឈានទៅដល់ការចាប់អារម្មណ៍របស់លោក **ស្បូត** អំពីប្រសិទ្ធភាពនៃការសម្ងាត់របស់ថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តនោះ។

### *ខ.២. លោក ខៀវ សំផន*

លោក **ស្បូត** បានបញ្ជាក់ថា ជនជាប់ចោទ **ខៀវ សំផន** បានប្រាប់គាត់ថា នៅដើមទសវត្សន៍ឆ្នាំ ១៩៦០ លោកមិនមែនជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជានោះទេ។ ប៉ុន្តែគាត់គឺជាសមាជិកនៃបក្សកុម្មុយនីស្តបារាំងនៅពេលលោកបានតែកំពុងសិក្សានៅប្រទេសបារាំង។ និក្ខេបបទបណ្ឌិតដែលគាត់បានសរសេរនៅក្នុងប្រទេសបារាំង "បានបង្ហាញឱ្យឃើញពីអនាគត" នូវផ្នែកដ៏ធំមួយនៃគោលនយោបាយសេដ្ឋកិច្ចសង្គមរបស់ខ្មែរក្រហម ដែលរួមបញ្ចូលទាំងការពឹងផ្អែកលើខ្លួនឯង និងសមភាពនិយមដ៏តឹងរឹង។ លោក **ស្បូត** បាន សង្កត់ធ្ងន់ថា គោលគំនិតដ៏សំខាន់នៃនិក្ខេបបទនេះ បានផ្តោតទៅលើជាតិទាំងមូលជាជាងបុគ្គលដែលជា គោលគំនិតឯករាជ្យខាងផ្នែកសេដ្ឋកិច្ច។ អ្នកជំនាញនេះ បានរម្លឹករឿងរ៉ាវមួយជាមួយសិស្សរបស់លោក **ខៀវ សំផន** ថា នៅពេលដែលជនជាប់ចោទ បានពន្យល់ពីដើមកំណើតនៃពាក្យកុម្មុយនីស្ត លោកបានកំណត់វាថាជា "បុគ្គលនិយម" ឬ មនុស្សគ្រប់គ្នាត្រូវតែដូចគ្នា។ ទោះជាយ៉ាងណាក៏ដោយ លោក **ស្បូត** បានព្រមានពីការបកស្រាយនិក្ខេបបទរបស់ជនជាប់ចោទថា ជាផែនការសម្រាប់គោលនយោបាយបក្សកុម្មុយនីស្តនាពេលអនាគត ប៉ុន្តែវាបានឆ្លុះបញ្ចាំងពីគំនិតដែលស្ថិតនៅក្រោមការពិភាក្សាក្នុងអំឡុងពេលនោះ។

បន្ទាប់ពីការវិលត្រឡប់របស់គាត់ ក្រុមគ្រួសាររបស់លោក **ខៀវ សំផន** ប្រាថ្នាចង់ឱ្យគាត់ក្លាយជាមន្ត្រីរដ្ឋាភិបាល។ ជំនួសឱ្យការធ្វើជាមន្ត្រីរដ្ឋាភិបាល ជនជាប់ចោទបានជ្រើសរើសធ្វើជាអ្នកកាសែតមួយ ហើយបានដំណើរការកាសែតឈ្មោះ **ឡឺអុំសារវ៉ាទ័រ** (L'Observateur) ដែលមានចំណាប់អារម្មណ៍ដល់បញ្ញាជននៅទីក្រុង ជាមួយនឹងការរិះគន់ដ៏ "ទន់ភ្លន់" ទៅលើ **សម្តេចសីហនុ**។ លោក **ស្បូត** បាននិយាយថា លោក **ខៀវ សំផន** បានបង្កើតកេរ្តិ៍ឈ្មោះនៅក្នុងប្រទេសកម្ពុជាជាបុរសដែលមាន "សុចរិតភាព" និង "កិត្តិយស" ជាអ្នកមិនងាយទទួលរងការបំភិតបំភ័យងាយស្រួលទេ និងជាអ្នកដែលបានជឿថា មានប្រព័ន្ធយុត្តិធម៌សម្រាប់ប្រទេសជាតិ។ ជាលទ្ធផលនៃគោលជំហររបស់គាត់ លោក **ខៀវ សំផន** ត្រូវបានគេដកហូតចេញ ហើយត្រូវបានបំបាក់មុខជាសាធារណៈ ដែលនាំឱ្យមានការសម្រេចចិត្តចូលរួមការតស៊ូ និងរត់គេចចេញពីភ្នំពេញ។

ដោយយោងទៅតាម "សៀវភៅប្រវត្តិសាស្ត្រ" នៅក្នុងទសវត្សន៍ឆ្នាំ១៩៦០ លោក **ខៀវ សំផន** បានទទួលការចាត់តាំងពីគណកម្មាធិការកុម្មុយនីស្តទីក្រុងភ្នំពេញនៅក្នុងព្រៃ ដើម្បីគៀងគរការគាំទ្រពីក្រុមបញ្ញវន្ត

និងអ្នកគាំទ្រ។[27] លោក **ស្បួត** បានបញ្ជាក់ពីរឿងនេះ ប៉ុន្តែបានគូសបញ្ជាក់ថា ព័ត៌មានលម្អិតថា នរណាបានទាក់ទងទៅកាន់ជនជាប់ចោទនេះ គឺមិនច្បាស់លាស់ភ្លាមៗទេ។ ខណៈពេលដែលគេបានដឹងថា ជនជាប់ចោទរួមជាមួយនឹង **ហ៊ូ យុន** និង **ហ៊ូ នឹម** ជាបញ្ញវន្តទាំងឡាយ ដែលមានសមានចិត្ត ដើម្បីបុព្វហេតុកុម្មុយនីស្តនេះ គឺនៅឆ្នាំ១៩៦៧ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានលាក់ទុកលោក **ខៀវ សំផន** នៅក្នុងភូមិដាច់ស្រយាល ដែលទំនាក់ទំនងរបស់គាត់ និងបក្សកុម្មុយនីស្តកម្ពុជាកាន់តែច្បាស់។ បន្ទាប់ពីការបះបោរនៅសំឡូត ដែលបានកើតឡើងនៅឆ្នាំនោះលោក **ខៀវ សំផន** បានផ្លាស់ទៅកាន់ភ្នំឱរ៉ាល់ ហើយបន្ទាប់មកទៅកាន់ភូមិភាគព្សសាននៅជិតខេត្តកំពង់ធំ ដែលជាទីតាំងការិយាល័យរបស់ **ប៉ុល ពត**។ បើយោងតាមលោក **ស្បួត** បានបង្ហាញឱ្យឃើញថា **ខៀវ សំផន** ត្រូវបានគេជឿទុកចិត្តច្រើនជាង **ហ៊ូ យុន** និង **ហ៊ូ នឹម** ដោយសារតែគាត់បានខិតចូលទៅកាន់តែជិត **ប៉ុល ពត**។ លោក **ស្បួត** បានថ្លែងថា **ប៉ុល ពត** គឺជាមនុស្សម្នាក់ដែលបានលើកទឹកចិត្តលោក **ខៀវ សំផន** ឱ្យរៀបការ ហើយជនជាប់ចោទបានធ្វើតាម។

លោក **ស្បួត** បានផ្តល់សក្ខីកម្មថា នៅចន្លោះឆ្នាំ១៩៧០ និងឆ្នាំ១៩៧៥ លោក **ខៀវ សំផន** គឺជា "មេដឹកនាំដែលមានប្រយោជន៍យ៉ាងខ្លាំង" សម្រាប់បក្សកុម្មុយនីស្តកម្ពុជា។ គាត់បានក្លាយជាអ្នកជំនួស និងសមាជិក និងមិនមែនជាសមាជិកដែលមានសិទ្ធិបោះឆ្នោតនៅគណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជាទេនៅក្នុងឆ្នាំ១៩៧៣។ លោក **ស្បួត** បានសង្កត់ធ្ងន់នៅពេលនោះថា លោក **ខៀវ សំផន** មិនត្រឹមតែមិនជិតស្និទ្ធនឹងគណៈអចិន្ត្រៃយ៍នោះទេ ហើយក៏គ្មានតួនាទីធ្វើការសម្រេចចិត្តដ៏សំខាន់ណាមួយទេ។ លោក **ខៀវ សំផន** បានថ្លែងក្នុងនៅពេលសម្ភាសន៍ទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងឆ្នាំ២០០៧ ថាការទទួលខុសត្រូវដ៏សំខាន់នៅចន្លោះឆ្នាំ១៩៧០ និងឆ្នាំ១៩៧៥ គឺការទាក់ទងជាមួយនឹង **សម្តេចសីហនុ** ដែលត្រូវបានគេបង្ហាញថា ជាមេដឹកនាំនៃការតស៊ូ។ លោកបានកាន់តួនាទីជាអនុប្រធាននៃរណសិរ្សរួបរួមជាតិកម្ពុជា និងជាកងមេបញ្ជានៃកងទ័ពរំដោះប្រជាជនកម្ពុជា។ លោក **ស្បួត** បានរៀបរាប់ពីតំណែង **ខៀវ សំផន** នៅពេលនោះថាជា "ជានិមិត្តរូបតែប៉ុណ្ណឹងទេ"។

ចំពោះតួនាទីរបស់ជនជាប់ចោទក្នុងការសម្រេចចិត្តលើការជម្លៀសប្រជាជនចេញពីទីភ្នំពេញ លោក **អាប់ឌុលហាក់** បានសំដៅលើសាក្សី **ភី ភួន** ថា **ប៉ុល ពត** និង **នួន ជា** ហើយនិង **ខៀវ សំផន** និងមេដឹកនាំកងទ័ពនានា បានចូលរួមក្នុងកិច្ចប្រជុំមួយនៅឯការិយាល័យ៨៥ នៅដើមខែមេសា ឆ្នាំ១៩៧៥ ហើយមេដឹកនាំទាំងបីរូបនេះ បានសម្រេចថា វិធានការនេះនឹងត្រូវធ្វើ។[28] ខណៈពេលដែល លោក **ស្បួត** មិនបានដឹងអំពីកិច្ចប្រជុំនេះ គាត់បានថ្លែថា **ប៉ុល ពត** និង **នួន ជា** អាចជាអ្នកដែលបានធ្វើសម្រេចចិត្តនោះ។ អ្នកជំនាញ ត្រូវបានសួរបន្ថែមទៀតទាក់ទងនឹងការថ្លែងសុន្ទរកថារបស់លោក **ខៀវ សំផន** ដែលបានធ្វើឡើង មុនពេលការដួលរលំទីក្រុងភ្នំពេញ លោក **ស្បួត** បានផ្តល់ចម្លើយថា វាជាផ្នែកមួយនៃតួនាទីរបស់ **ខៀវ សំផន** ជាការជួបមុខជាសាធារណៈរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងជាពិសេស វាគឺជាស្នូលបក្សកុម្មុយនីស្តរបស់ខ្លួន។ លោក **ស្បួត** បានបន្ថែមទៀតថា សុន្ទរកថារបស់ **ខៀវ សំផន** ក៏មានអត្ថន័យបង្ហាញពីសារមួយជាក់លាក់មួយចំនួនឧទាហរណ៍ មានតែ "ជនក្បត់ប្រាំពីរ" នឹងត្រូវបានសម្លាប់។

លោក **ស្បួត** បានបញ្ជាក់ថា ក្រោយឆ្នាំ១៩៧៥ លោក **ខៀវ សំផន** បានក្លាយជាសមាជិកពេញលេញ និងមានសិទ្ធិបោះឆ្នោតនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ លោក **ស្បួត** បានផ្តល់

ចម្លើយថា នៅពេលដែលលោក **ខៀវ សំផន** បានចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ជាច្រើនលើក លោក **ខៀវ សំផន** មិនមែនជាសមាជិកនៃគណៈអចិន្ត្រៃយ៍នោះទេ។ បើទោះបីជាលោក **ខៀវ សំផន** បានក្លាយជាប្រមុខរដ្ឋនៅក្នុងឆ្នាំ១៩៧៦ យ៉ាងណាមិញ ក៏លោក **ស្សុត** បានសង្កត់ធ្ងន់ថា "តួនាទីរបស់គាត់មិនគួរត្រូវបានបំផ្លើស" នោះទេ។ លោក **ស្សុត** បាននិយាយថា ការឃោសនាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ **យុន យ៉ាត** ជាភរិយារបស់លោក **សុន សេន**។ ទោះជាយ៉ាងណាក៏ដោយ មេដឹកនាំទាំងអស់រួមទាំង លោក **ខៀវ សំផន** ជាអ្នកទទួលខុសត្រូវចំពោះវគ្គសិក្សា។ លើសពីនេះទៀត នៅពេលដែលសួរសំណួរដែលទាក់ទង នឹងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍អំពីបញ្ហាព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម លោក **ស្សុត** បានឆ្លើយតបថា លោក **ខៀវ សំផន** មិនបាននិយាយទេ ពីព្រោះគាត់មិនមែនជាផ្នែក "ស្នូលនៃការធ្វើសេចក្តីសម្រេចចិត្ត" ទាក់ទងទៅនឹងកងទ័ព។

បន្ទាប់ពីលោក **ខឿន** ជាប្រធានការិយាល័យនយោបាយលេខ៨៧០ ត្រូវបានចាប់ខ្លួន លោក **ស្សុត** មិនប្រាកដទេថា ប្រសិនបើមានការផ្លាស់ប្តូរជាផ្លូវការណាមួយ។ ទោះជាយ៉ាងណាក៏ដោយ លោកបានបង្ហាញថា វាសមហេតុផលដើម្បីសន្មតថា លោក **ខៀវ សំផន** មានតួនាទីយ៉ាងសំខាន់ក្នុងការិយាល័យនោះ។ គាត់បានសន្និដ្ឋានរឿងនេះដោយផ្អែកលើព័ត៌មាន ដែលគាត់បានយកមកពីបណ្ណសាររបស់វៀតណាម ក៏ដូចជាការសម្ភាសន៍ជាមួយនឹងប្រភពផ្សេងទៀត។ អ្នកជំនាញក៏បានពិចារណាការទទូចរបស់ជនសង្ស័យ **ខៀវ សំផន** ក្នុងអំឡុងពេលសម្ភាសន៍របស់ពួកគេ ដោយគាត់មិនមានអ្វីដែលទាក់ទងជាមួយនឹងការិយាល័យនោះទេ។ លោក **ស្សុត** បានបញ្ជាក់ថា ជាសមាជិកនៃការិយាល័យទូទៅ **ប៉ុល ពត** បានបញ្ជូនជនជាប់ចោទឱ្យធ្វើ "បេសកកម្មដ៏លំបាក" គឺទៅកាន់ភូមិភាគ និងខេត្តនានា នៅពេលដែលមានបញ្ហាផ្នែកនយោបាយចាំបាច់ត្រូវដោះស្រាយ ឬស៊ើបអង្កេត។ ទោះជាយ៉ាងណាក៏ដោយ លោក **ខៀវ សំផន** គ្មានសិទ្ធិអំណាចដើម្បីធ្វើការសម្រេចចិត្តលើបញ្ហានយោបាយនានា និងរាយការណ៍ពីលទ្ធផលនៃការស៊ើបអង្កេតរបស់គាត់ទៅកាន់ **ប៉ុល ពត**។

បើទោះបីជាលោក **ខៀវ សំផន** ហាក់ដូចជាគ្មានសិទ្ធិអំណាចដើម្បីធ្វើការសម្រេចចិត្តទេ លោក **ស្សុត** បានចាត់ថ្នាក់លោក **ខៀវ សំផន** ក្នុងចំណោមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ អ្នកជំនាញបានពិពណ៌នា **ខៀវ សំផន** ជា "ស្មៀនលេខាធិការការី" អ្នកដែលគេជឿទុកចិត្តថា "នៅជាមួយពួកគេ ប៉ុន្តែមិនមែនជាគ្នីគ្នារបស់ពួកគេ"។[29] លោក **ស្សុត** បានរៀបរាប់ថា **ប៉ុល ពត** ជឿទុកចិត្ត **ខៀវ សំផន** ដោយសារតែ "គាត់អាចពឹងផ្អែកលើអ្វីដែល **ខៀវ សំផន** បានប្រាប់គាត់"។[30] លោក **ខៀវ សំផន** បានក្លាយជាកូនសិស្សរបស់ **ប៉ុល ពត** បន្តិចម្តងៗ។ នៅចំពេលមួយ អតីតលេខាធិការបក្សកុម្មុយនីស្តកម្ពុជា អាចពិចារណាថា លោក **ខៀវ សំផន** ជាអ្នក "ស្នងតំណែង" របស់គាត់។ ទោះជាយ៉ាងណាក៏ដោយ រឿងនេះមិនបានកើតឡើងទេ ដោយសារតែហេតុផលផ្សេងៗ ហើយហេតុផលមួយអាចថាលោក **ខៀវ សំផន** ជា "អ្នកដើរតាមដ៏ល្អប្រសើរជាងជាអ្នកដឹកនាំ"។ លោក **ស្សុត** ក៏បានសង្កត់ធ្ងន់ថា ជនជាប់ចោទធ្វើបានល្អចំពោះតួនាទីនេះ។ លោកបានពិពណ៌នា លោក **ខៀវ សំផន** ថា ជាមនុស្ស "រឹងមាំ ប្រកាន់លទ្ធិខ្ជាប់ខ្ជួនប៉ុន្តែ បិតបេរ"[31] ជាបុគ្គលម្នាក់ដែលប្រកាន់ខ្ជាប់នូវអ្វីដែលខ្លួនជឿជាក់ "ដោយមិនចាំបាច់សួរសំណួរច្រើនដង"។[32] ពាក់ព័ន្ធនឹងការចូលរួមរបស់ **ខៀវ សំផន** នៅក្នុងការសម្រេចចិត្តក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ លោក **ស្សុត** បានបន្តថា:

*គាត់ជាភាគីមួយនៃសេចក្ដីសម្រេច ទោះបីជាគាត់មិនបានជាអ្នកធ្វើទេ គឺថាគាត់មិនដែលជំទាស់ទេ ខ្ញុំយល់ហើយថា គាត់ពិបាកនឹងជំទាស់ណាស់ បើជំទាស់អាចប្រឈមនឹងគ្រោះថ្នាក់។ គេគ្របបណ្ដប់ថា សេចក្ដីសម្រេចទាំងអស់នោះ ធ្វើឡើងដោយបក្សកុម្មុនីស្ដកម្ពុជា។ នៅតាមន័យនោះ គាត់ជាសមាជិកមួយនៅក្នុងនោះ ហើយគាត់មិនដែលបានខ្វែងមតិជាមួយសេចក្ដីសម្រេចនោះទាំងអស់នោះទេ។*[33]

## ឍ. អាកប្បកិរិយា និងភាពគួរឱ្យជឿបានរបស់សាក្សី

លោក **ហ្វីលីព ស្បូត** ចង់ដឹងចង់ឃើញអំពីរបបកម្ពុជាប្រជាធិបតេយ្យក្នុងទស្សវត្សន៍ឆ្នាំ១៩៧០ នៅពេលដែលគាត់ធ្វើការជាអ្នកកាសែតនៅក្នុងប្រទេសចិន។ អ្នកជំនាញ បានស្គាល់ឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសចិន ហើយបានមកតាមយកព័ត៌មានពីមេដឹកនាំខ្មែរក្រហមដែលមកទស្សនកិច្ចនៅប្រទេសចិននៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧។[34] ទោះជាយ៉ាងណាក៏ដោយ គាត់បានទទួលស្គាល់ថា គាត់មិនដែលមកទស្សនកិច្ចនៅប្រទេសកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហមទេ ដោយសារតែការខិតខំទទួលបានទិដ្ឋាការរបស់លោក គឺមិនទទួលបានជោគជ័យ។ ប៉ុន្តែ ដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជាលើកដំបូងរបស់អ្នកជំនាញ គឺនៅក្នុងឆ្នាំ១៩៩៩ បន្ទាប់ពី **ប៉ុល ពត** បានស្លាប់។ អ្នកជំនាញ ក៏មិនចេះនិយាយភាសាខ្មែរទៀត ប៉ុន្តែ នេះមិនបានបង្កជាបញ្ហានោះទេ នៅពេលដែលគាត់បានសម្ភាសជនជាប់ចោទ ពីព្រោះលោក **អៀង សារី** និងលោក **ខៀវ សំផន** អាចនិយាយភាសាបារាំងបាន។ លោក **កូប៉េ** បានចោទសួរពីវគ្គបណ្ដុះបណ្ដាលការសិក្សារបស់លោក **ស្បូត** នៅក្នុងផ្នែកប្រវត្តិសាស្ត្រ និងកុម្មុយនីស្ត។ លោក **ស្បូត** បានទទួលស្គាល់ថា គាត់មិនបានទទួលការបណ្ដុះបណ្ដាលវគ្គសិក្សាផ្លូវការណាមួយទៅលើមុខវិជ្ជាទាំងពីរនោះទេ ហើយលោកក៏មិនធ្លាប់បានសរសេរអត្ថបទទាក់ទងនឹងទ្រឹស្ដីកុម្មុយនីស្តដែរ។ អ្នកជំនាញ បានបញ្ជាក់ថា គាត់បានធ្វើការពិនិត្យឡើងវិញនូវអត្ថបទស្រដៀងៗគ្នានៅលើប្រធានបទនេះ ហើយបានទទួលចំណេះដឹងលទ្ធិកុម្មុយនីស្តនេះ ខណៈពេលដែលធ្វើការជាអ្នកយកព័ត៌មានក្នុងប្រទេសរុស្ស៊ី ហើយនិងប្រទេសចិន ក៏ដូចជានៅពេលធ្វើការស្រាវជ្រាវសម្រាប់សៀវភៅរបស់គាត់ផងដែរ។ សៀវភៅមួយក្នុងចំណោមសៀវភៅរបស់គាត់ មានចំណងជើងថា "នាគ និងខ្លាឃ្មុំ" គឺជាការសិក្សាប្រៀបធៀបរវាង ប្រព័ន្ធប្រទេសចិនក្រោយពីលទ្ធិម៉ៅ និងប្រព័ន្ធប្រទេសរុស្ស៊ីក្រោយលទ្ធិស្តាលីន។ ដោយប្រៀបធៀបកិច្ចការរបស់គាត់ជាមួយនឹងការងាររបស់អ្នកជំនាញផ្សេងទៀត លោក **ហ្វីលីព ស្បូត** បានថ្លែងថា លោកមានភាពខុសគ្នាពីសាស្ត្រាចារ្យ **ដេវីដ ឆេនដ៍ល័រ** និងលោក **ស្ទីវ ហេដឌ័រ** ឬលោក **ប៊ែនឃៀរនិន** (Mr. Ben Kiernan) ដោយសារតែកិច្ចការរបស់ពួកគេផ្ដោតតែទៅលើប្រទេសកម្ពុជា ចំពោះគាត់វិញ បានរៀនហើយរស់នៅក្រោមប្រព័ន្ធកុម្មុយនីស្ត ហើយនិងវប្បធម៌ផ្សេងៗគ្នា។

ចំពោះប្រភពនានានៃសៀវភៅរបស់លោក **ស្បូត** គាត់បានពន្យល់ថា គាត់បានប្រមូលព័ត៌មានពីការសម្ភាសន៍ប្រជាជនក៏ដូចជាការពិនិត្យឡើងវិញនូវឯកសារទាំងឡាយ រួមទាំងចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១។ លោកបានថ្លែងថា "ចំណុចនៃ...សៀវភៅបែបនេះ គឺវាដូចជាគំនូរផ្គុំតូចៗនៃផ្នែកល្អិតៗនៃព័ត៌មាន ដែលអ្នកព្យាយាមដាក់រួមបញ្ចូលគ្នាអញ្ចឹង។ ហើយប្រសិនបើអ្នកសួរខ្ញុំឥឡូវនេះ ខ្ញុំមិនអាចប្រាប់អ្នកឱ្យបានច្បាស់ថា តើវាបានមកពីប្រភពណានោះទេឥឡូវនេះ។[35] អ្នកជំនាញ ក៏បានទទួលស្គាល់ផងដែរថា

គាត់បានយកជម្រើស មិនសម្ភាសជនរងគ្រោះដោយចេតនា នៅពេលដែលគាត់កំពុងសរសេរ "សៀវភៅប្រវត្តិសាស្ត្រ" បើទោះបីជា លោកបានដកស្រង់រឿងរ៉ាវមួយចំនួនធំដែលគេបានបោះពុម្ពផ្សាយរួចទៅហើយ។

## ផ្នែកទី ៣ ៖ បញ្ហានីតិវិធី និងច្បាប់

គ្មានបញ្ហានីតិវិធីច្បាប់សំខាន់ទេនៅសប្តាហ៍នេះ ទោះបីជាសង្កេតឃើញ ការិយាល័យសហព្រះរាជអាជ្ញា បានលើកឡើងការជំទាស់គួរឱ្យកត់សម្គាល់ជាច្រើនក្នុងអំឡុងពេលនៃការសួររបស់ក្រុមមេធាវីការពារក្តី ប៉ុន្តែ នៅពេលខាងព្រះរាជអាជ្ញាវិញសួរសំណួរវិញ បានដំណើរការទៅដោយពុំមានការរំខានទេ។ ការិយាល័យសហព្រះរាជអាជ្ញា បានជំទាស់ជាពិសេសចំពោះសំណួរដែលមិនទាក់ទងទៅនឹងសំណុំរឿងដែលកំពុងតែជំនុំជម្រះ ហើយអង្គជំនុំជម្រះភាគច្រើនបានគាំទ្រចំពោះការជំទាស់របស់សហព្រះរាជអាជ្ញា។

### ក. ការជំទាស់ទៅលើសំណួរពីអង្គជំនុំជម្រះ

នៅថ្ងៃចន្ទ លោក **កូប៉េ** សហមេធាវីអន្តរជាតិការពារក្តីឲ្យលោក **នួន ជា** បានសង្កេតឃើញថា ចៅក្រម **ស៊ីលវៀ ខាតវ៉ាយថ៍** កំពុងតែស្វែងរកព័ត៌មានដែលហួសពីជំនាញរបស់លោក **ស្បូត**។ សហមេធាវីអន្តជាតិ បានដឹងថា ការជំទាស់ទៅនឹងសំណួររបស់ចៅក្រមមិនត្រូវបានគេអនុញ្ញាតទេ ប៉ុន្តែ គាត់បានដាក់សំណើសួរ អំពីរយៈពេលថាតើប៉ុន្មានថ្ងៃជាក់លាក់ដែលត្រូវការដើម្បីជម្លៀសប្រជាជន និងដើម្បីតាំងទីលំនៅថ្មីឱ្យប្រជាជនទាំងនោះ គឺមិននៅស្ថិតនៅក្នុងជំនាញរបស់អ្នកជំនាញ ដូចជាអ្នកប្រវត្តិសាស្ត្រនោះទេ។ ចៅក្រម បានទទួលស្គាល់ពីបញ្ហានេះ ហើយបានប្រកាសថា នឹងមិនបន្តសំណួរនេះទៀតទេ ប៉ុន្តែ បានការពារថា វាជាសំណួរមួយដែលលោក **ស្បូត** អាចឆ្លើយបានដោយប្រើប្រាស់ "សុភវិនិច្ឆ័យ" របស់គាត់។

### ខ. ការជំទាស់ពាក់ព័ន្ធទៅនឹងសំណួរមិនទាក់ទង

ក្នុងអំឡុងពេលនៃការសាកសួររបស់ក្រុមមេធាវីការពារក្តីទាំងពីរទៅលើសាក្សី ពួកគេប្រឈមមុខចំពោះការជំទាស់ និងការសម្រេចនានា ដែលបានហាមឃាត់មិនឲ្យសួរសំណួរមួយចំនួន ដែលចាត់ទុកថា មិនមានការជាប់ទាក់ទងនឹងរឿងក្តីនៅក្នុងសវនាការ។ រឿងនេះបានកើតឡើងនៅរាល់ពេលដែលក្រុមមេធាវីការពារក្តី បានព្យាយាមលើកសំណួរប្រៀបធៀបអំពើយង់ឃ្នងក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យជាមួយបណ្តាលប្រទេសកុម្មុយនីស្តផ្សេងទៀត ឬឧបករណ៍សម្របសម្រួលរបស់ អ.វ.ត.ក នៅក្នុងការទាមទាររកយុត្តិធម៌។ លោក **កូប៉េ** បានសួរទៅកាន់លោក **ស្បូត** ដើម្បីប្រៀបធៀបពីសកម្មភាពរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងពេលសម័យកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងមេដឹកនាំកុម្មុយនីស្តចិនក្នុងអំឡុងពេលមហាលោតផ្លោះមហាអស្ចារ្យ និងបដិវត្តន៍វប្បធម៌ ជាមួយនឹងការអត្ថាធិប្បាយលើកឡើងមុនថា វាហាក់ដូចជា "អយុត្តិធម៌" ដែលមេដឹកនាំចិន មិនត្រូវបានគេកាត់ទោស។ លោក **អាប់ឌុលហាក់** សហព្រះរាជអាជ្ញាអន្តរជាតិ បានជំទាស់ដោយនិយាយថា ការអត្ថាធិប្បាយមុនសំណួរនេះគឺ "មិនសមរម្យ" ទេ ព្រោះមេធាវីមិនគួរដាក់ការវិនិច្ឆ័យលើ "អ្នកណាគួរតែត្រូវបានកាត់ទោសនៅក្នុងប្រទេសណានោះឡើយ"។ បើទោះបីជា ការ

ស្នើសុំរបស់លោក **កូប៉េ** ដើម្បីទទួលឲ្យបាន "ព័ត៌មានបន្ថែម" យ៉ាងណាមិញ ក៏លោក **និល ណុន** ប្រធានអង្គជំនុំជម្រះ បានសម្រេចថា សំណួរទាំងអស់គឺមិនពាក់ព័ន្ធ ហើយបានប្រាប់មេធាវីការពារក្តីឱ្យបន្ត។ មេធាវីការពារក្តី ក៏បានព្យាយាមផ្ទៀងផ្ទាត់ ថាតើការសង្ស័យរបស់មេដឹកនាំខ្មែរក្រហមទាក់ទងនឹងខ្មាំងផ្ទៃក្នុង មិនមែនជាការនឹកឃើញដោយចៃដន្យទេ ដោយលោកបានដកស្រង់ឧទាហរណ៍ថា លោក **ហេង សំរិន** បានគេចខ្លួនទៅប្រទេសវៀតណាម ហើយក្រោយមកបានក្លាយជាប្រធាន។[36] លោក **អាប់ឌុលហាក់** បានចាត់ទុកថា សំណួរដែលទាក់ទងនូវព្រឹត្តិការណ៍ មុនរបបកម្ពុជាប្រជាធិបតេយ្យ និងក្រោយឆ្នាំ១៩៧៩ គឺមិនមានការជាប់ទាក់ទងទេក្នុងសំណុំរឿង លើកលែងតែតុលាការពិចារណាអំពីទ្រឹស្តីនៃការសមគំនិត។ ការជំទាស់មានប្រសិទ្ធភាព។

អ្នកស្រី **ហ្គីសសេ** មេធាវីការពារក្តីអន្តរជាតិឲ្យលោក **ខៀវ សំផន** បានព្យាយាមពីរដង ដើម្បីទាញយកគំនិតរបស់លោក **ស្នូត** ទៅលើបញ្ហាដំណើរការកាត់ក្តីនៅ អ.វ.ត.ក។ ជាដំបូង អ្នកស្រី បានសំដៅទៅលើអត្ថបទកាសែតភ្នំពេញប៉ុស្តិ៍ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០០ មានចំណងជើងថា "មេធាវីបិសាចមិនត្រូវមានការជម្រះសេចក្តីខ្មែរក្រហមទេ។" នៅក្នុងអត្ថបទនេះ លោក **ស្សូត** បានបង្ហាញនូវការជឿជាក់របស់គាត់ថា តុលាការអន្តរជាតិដែលត្រូវបានបង្កើតឡើង ដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម នឹងអាចជាឧបករណ៍ដើម្បី "ការសងសឹក តាមផ្លូវតុលាការ" សម្រាប់ជាប្រយោជន៍របស់អង្គការសហប្រជាជាតិ និងដើម្បីឱ្យសហរដ្ឋអាមេរិកស្ងប់ចិត្ត។ នៅក្នុងការព្យាយាមជាលើកទីពីរ មេធាវីការពារក្តី បានផ្អែកសំណួររបស់ខ្លួននៅលើការសម្ភាសន៍សាក្សី ដោយកាសែតភ្នំពេញប៉ុស្តិ៍ចុះថ្ងៃទី៧ ខែមិនា ឆ្នាំ២០១៣។ នៅក្នុងបទសម្ភាសន៍នេះ អ្នកជំនាញបានចោទសួរពីប្រសិទ្ធិភាពរបស់ អ.វ.ត.ក។ លោកបានកត់សម្គាល់ថា មានតែមេដឹកនាំខ្មែរក្រហមប៉ុណ្ណោះ ដែលបានយកទៅកាត់ទោស ហើយពុំមានយន្តការផ្សះផ្សារវាងជនរងគ្រោះ និងចារី ដែលប្រព្រឹត្តផ្ទាល់បានបន្តរស់នៅជិតគ្នារាល់ថ្ងៃ។ សហព្រះរាជអាជ្ញា **អាប់ឌុលហាក់** បានជំទាស់ទៅនឹងការព្យាយាមទាំងពីរនេះ ដោយថ្លែងថា សំណួរទាំងនេះគឺមិនពាក់ព័ន្ធ។ អ្នកស្រី **ហ្គីសសេ** បានអះអាងថា ទាក់ទងទៅនឹងអត្ថបទដំបូង វាមានសារៈសំខាន់ ដើម្បីស្វែងរកមតិយោបល់របស់អ្នកជំនាញទៅលើកសវនាការ ដែលគាត់កំពុងផ្តល់សក្ខីកម្ម។ អ្នកស្រី ក៏បានបង្ហាញដែរថា អត្ថបទមាននៅក្នុងសំណុំរឿង។ សម្រាប់សំណួរទីពីររបស់ អ្នកស្រីមេធាវីការពារលោក **ខៀវ សំផន** បានបន្តថា អ្នកស្រីបានកំពុងព្យាយាមស្វែងយល់ពីសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញថា អ្នកណាគួរតែយកមកជំនុំជម្រះ ហើយនិងការទទួលខុសចំពោះការដឹកនាំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សំណួរទាំងពីរ គឺមិនទាក់ទងទៅនឹងអង្គហេតុនៃសវនាការ និងហួសពីជំនាញរបស់សាក្សីអ្នកជំនាញ។

## ផ្នែកទី ៤៖ ការគ្រប់គ្រងសវនាការ

នាសប្តាហ៍នេះ អង្គជំនុំជម្រះ បានរៀបចំកិច្ចដំណើរការនីតិវិធីយ៉ាងរលូនជាមួយនឹងសេចក្តីសន្និដ្ឋានរបស់សាក្សីជំនាញលោក **ហ្វីលីព ស្សូត**។ មានបញ្ហាច្បាប់ និងនិតិវិធីពីរបី ដែលបានលើកឡើង ហើយនិងកិច្ចពិភាក្សាក្នុងចំណោមភាគីនានា បានធ្វើឡើងនៅក្នុងបរិយាកាសធម្មតា។ ជាការកត់សម្គាល់ ឃើញមាន

ការលំបាកក្នុងការយល់ជាភាសាអង់គ្លេស និងភាសាខ្មែរ ដែលបានប្រែពីភាសាបារាំង និយាយដោយចៅក្រមបារាំង។

### ក. វត្តមាន

លោក **នួន ជា** បានចូលរួមតាមដានក្នុងដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការអស់រយៈពេលពេញមួយសប្ដាហ៍។ លោក **ខៀវ សំផន** បានសង្កេតយ៉ាងសកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីនៅក្នុងបន្ទប់សវនាការពេញមួយសប្ដាហ៍។

***វត្តមានដើមបណ្ដឹងរដ្ឋប្បវេណី៖*** ដើមបណ្ដឹងរដ្ឋប្បវេណី បានតាមដានកិច្ចដំណើរការនីតិវិធីនៅក្នុងបន្ទប់សវនាការពេញមួយសប្ដាហ៍។ លើសពីនេះទៀត មានដើមបណ្ដឹងរដ្ឋប្បវេណីប្រមាណ ៧០នាក់ មកពីខេត្តកំពង់ចាម និងខេត្តបាត់ដំបង នៅថ្ងៃចន្ទ និងមាន១០នាក់ បានតាមដានកិច្ចដំណើរការសវនាការ នៅថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍។

***វត្តមានរបស់ភាគី ៖*** រាល់ភាគីទាំងអស់ ត្រូវបានតំណាងនៅពេញមួយសប្ដាហ៍នេះ។

***វត្តមានសាធារណជន ៖***

| កាលបរិច្ឆេទ | ពេលព្រឹក | ពេលរសៀល |
|---|---|---|
| ថ្ងៃចន្ទ<br>០៦/០៥/១៣ | សិស្សនិស្សិត៣០០នាក់មកពីស្រុកស្ទឹងត្រែង ខេត្តកំពង់ចាម<br>អ្នកសង្កេតការណ៍បរទេសមាន ជាង១៥នាក់ | អ្នកភូមិប្រហែល១០០នាក់មកពីស្រុកកំពង់ត្រឡាច ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង<br>អ្នកសង្កេតការណ៍បរទេសមាន ជាង១០នាក់ |
| ថ្ងៃអង្គារ<br>០៧/០៥/១៣ | អ្នកភូមិប្រហែល៤០០នាក់មកពីខេត្តព្រៃវែង<br>អ្នកសង្កេតការណ៍បរទេសមាន៥នាក់ | អ្នកស្រុកប្រហែលជា១៧០ នាក់មកពីខេត្តតាកែវ<br>អ្នកសង្កេតការណ៍បរទេសមាន២នាក់ |
| ថ្ងៃពុធ<br>០៨/០៥/១៣ | សិស្សចំនួន៤០០នាក់ បានមកពីខេត្តព្រះសីហនុ និងខេត្តកំពង់ចាម<br>អ្នកភូមិ ៥០ នាក់ មកពីខេត្តកំពត<br>អ្នកសង្កេតការណ៍បរទេសមាន៩នាក់<br>អ្នកសង្កេតការណ៍ វី. អាយ. ភី ចំនួន ៥នាក់ | អ្នកភូមិជនជាតិចាមភាគតិច១៥០នាក់មកពីខេត្តតាកែវ |
| ថ្ងៃព្រហស្បតិ៍<br>០៩/០៥/១៣ | អ្នកភូមិ ៣៧០នាក់មកពីខេត្តបាត់ដំបង និងខេត្តតាកែវ | អ្នកសង្កេតការណ៍បរទេសមាន៥នាក់ |

### ខ. ការគ្រប់គ្រងពេលវេលា

នៅសប្ដាហ៍នេះអង្គជំនុំជម្រះ បានបន្តកិច្ចដំណើរការនីតិវិធីពីថ្ងៃចន្ទដល់ថ្ងៃព្រហស្បតិ៍ និងបានចាប់ផ្ដើមកិច្ចសវនាការយ៉ាងទៀងទាត់ស្ទើរតែគ្រប់វគ្គទាន់ពេលវេលា។ លើសពីនេះទៀត បើទោះបីជាតុលាការហាក់ដូចជាតឹងរឹងខ្លាំងនៅក្នុងគ្រប់គ្រងពេលវេលាដែលបានផ្ដល់ជូនសម្រាប់ឱ្យភាគី វាហាក់ដូចជាមានការ

លំបាកយល់ដែល ភាគីប្រឈមមុខនៅក្នុងការកាត់បន្ថយសំណួររបស់ពួកគេដោយសារតែស្មុគស្មាញ និងការគ្របដណ្តប់វិសាលភាពធំធេងនៃសក្ខីកម្មរបស់លោក **ហ្វីលីព ស្សូត**។ ដូច្នេះ តុលាការបានផ្តល់កន្លះម៉ោងបន្ថែមទៀត ដោយមានការស្នើសុំពីក្រុមមេធាវីការពារក្តីនីមួយៗ។

## គ. បញ្ហាបច្ចេកទេស និងការបកប្រែ

សប្តាហ៍នេះ មានបញ្ហាបច្ចេកទេសតិចតួចបានកើតឡើងជាញឹកញាប់។ សំឡេងមិនលឺពីប្រព័ន្ធសោត ទស្សន៍ (អូឌីយ៉ូវីដេអូ) ប្រហែលប្រាំនាទីនៅថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍ ខណៈដែលមីក្រូហ្វូនរបស់អ្នកជំនាញ មានបញ្ហាញឹកញាប់។

នៅរសៀលថ្ងៃចន្ទក្នុងអំឡុងពេលសាកសួរដោយចៅក្រម **ហ្សង់ម៉ាក ឡាវ៉ាញ** (Judge Jean-Marc Lavergne) ប្រធានអង្គជំនុំជម្រះ បានអនុញ្ញាតលោក **ហ្វីលីព ស្សូត** ផ្តល់សក្ខីកម្មជាភាសាបារាំង ពីព្រោះអ្នកជំនាញចេះពីរភាសា។ ចាប់ពីពេលនិយាយភាសាបារាំងនោះមក សង្កេតឃើញថា សក្ខីកម្មរបស់អ្នកជំនាញកាន់តែពិបាកក្នុងការយល់។ កាលពីថ្ងៃព្រហស្បតិ៍ ក្នុងអំឡុងពេលអ្នកស្រី **ហ្គីសសេ** សាកសួរលោក **ស្សូត** សហព្រះរាជអាជ្ញាអន្តរជាតិ **អាប់ឌុលហាក់** បានចង្អុលបង្ហាញថា សេចក្តីដកស្រង់លើសេចក្តីថ្លែងការណ៍របស់លោក **ខៀវ សំផន** ដែលបានធ្វើឡើងជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតថា អ្នកស្រី **អាណាតា ហ្គីសសេ** មិនបានលើកឡើងពីអង្គហេតុថា លោក **ខៀវ សំផន** បានទទួលស្គាល់ថា ខ្លួនមានសមាជិកភាពនៅក្នុងការិយាល័យ ៨៧០ នោះទេ។ អ្នកស្រី **ហ្គីសសេ** បានអះអាងទៅដល់អង្គជំនុំជម្រះថា អ្នកស្រីបានអានសេចក្តីដកស្រង់ទាំងអស់ ដោយលើកឡើងថាមានបញ្ហាយ៉ាងខ្លាំងជាមួយនឹងការបកប្រែភាសា។

## ឃ. តារាងពេលវេលា

| កាលបរិច្ឆេទ | សវនាការទី១ ពេលព្រឹក | សវនាការទី២ ពេលព្រឹក | សវនាការទី១ ពេលរសៀល | សវនាការទី២ ពេលរសៀល | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|
| ថ្ងៃចន្ទ ០៦/០៥/១៣ | ៩:០១-១០:៤០ | ១១:០១-១២:០០ | ១៣:៣០-១៤:៤០ | ១៥:០១-១៦:១២ | ៤ម៉ោងនិង ៥៩នាទី |
| ថ្ងៃអង្គារ ០៧/០៥/១៣ | ៩:០២-១០:២៩ | ១០:៥០-១២:០១ | ១៣:៣៣-១៤:៣៩ | ១៥:០០-១៦:០២ | ៤ម៉ោងនិង ៤៦នាទី |
| ថ្ងៃពុធ ០៨/០៥/១៣ | ៩:០២-១០:៣៤ | ១០:៥៧-១២:១៣ | ១៣:៣២-១៤:៥៨ | ១៥:២០-១៦:៣០ | ៥ម៉ោងនិង ២៤ នាទី |
| ថ្ងៃព្រហស្បតិ៍ ០៩/០៥/១៣ | ៩:០២-១០:៣៣ | ១០:៥៥-១២:០១ | ១៣:៣២-១៤:៥៧ | ១៥:២៣-១៦:៤៥ | ៥ម៉ោងនិង ២៤ នាទី |
| ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយថ្ងៃ៖ ***៥ម៉ោង និង ៨នាទី*** | | | | | |
| ចំនួនម៉ោងសរុបក្នុងសប្តាហ៍នេះ៖ ***២០ម៉ោង និង៣៣នាទី*** | | | | | |
| ចំនួនសរុបនៃម៉ោងថ្ងៃនិងសប្តាហ៍៖ ***៧៦២ ម៉ោង និង១៧នាទី*** | | | | | |
| **១៧៦ថ្ងៃ ក្នុងអំឡុងពេល៥៥សប្តាហ៍** | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

[1] Trial Chamber. Transcript of Trial Proceedings (6 May 2013). E1/189.1 [hereinafter 6 MAY TRANSCRIPT].Lines 5-14. 59.

[2] See CASE 002 KRT TRIAL MONITOR, Issue 54, Hearing on Evidence Week 49 (4 March 2013).

[3] President Nil Nonn referred to Trial Chamber. Consolidated schedule of witnesses and experts for early 2013 (8 January 2013). E236/4. The memorandum iacknowledged that the length of testimony for Philip Short, Elizabeth Becker, and Stephen Heder was shorter that what was originally announced and encouraged the parties to limit questioning only to those topics relevant to Case 002/01.

[4] The Prosecutor was quoting from page 137 of “History”.
[5] The Prosecutor was quoting from page 146 of “History”.
[6] The bombing ended in August 1973.
[7] Trial Chamber. Transcript of Trial Proceedings (7 May 2013). E1/190.1 [hereinafter 7 MAY TRANSCRIPT]. Line15. p. 2 National Prosecutor Veng Huot quoted from page 8-9 of “History”.
[8] International Prosecutor Abdulhak quoted from page 223 of “History”.
[9] Counsel Guisse cited from page 305 of “History”.
[10] See CASE 002 KRT TRIAL MONITOR. Issue 29. Hearing on Evidence Week 24 (23-26 July 2012) [hereinafter ISSUE 29].
[11] International Judge Sylvia Cartwright cited these policies from “History”, and Short explained that his knowledge of them were from sources ranging from other journalists, former KR cadres, and US intelligence reports.
[12] Phy Phuon, an alias of Witness Rochoem Ton, testified before the ECCC in July and August 2012. See ISSUE 29 and CASE 002 KRT TRIAL MONITOR, Issue 30, Hearing on Evidence Week 25 ( (30-31 July, 1-2 Aug 2012) [hereinafter ISSUE 30].
[13] Judge Cartwright cited this from “History” page 260.
[14] Judge Cartwright cited from page 255 and 257 of Short’s book that Kratie was evacuated in the second half of 1973, and after KR attacked Kampong Cham, 15,000 town dwellers were taken to liberated zones. During attack of Udong 20,000 people from the city were resettled in cooperatives, and 40,000 from the Northern Zone fled from there to Kampong Thom.
[15] Trial Chamber. Transcript of Trial Proceedings (6 May 2013). E1/189.1 [hereinafter 6 MAY TRANSCRIPT] Line 12-14. 31.
[16] Prosecutor Abdulhak quoted passages from page 308-309 of “History”.
[17] 7 MAY TRANSCRIPT Line 19. 30.
[18] Bizot testified before the Chamber during Case 001 against Duch, former Chairman of S-21. See CASE 001 KRT TRIAL MONITOR. Issue 3. Hearing on Evidence Week 2. (6-10 April 2009)
[19] 6 MAY TRANSCRIPT Line 22-25. 20.
[20] Prosecutor Abdulhak explained that this issue was published in East Zone in June 1974, the particular article quoted was "Strengthening and Improving the Party's Leadership Stance and Leadership Attitude".
[21] 7 MAY TRANSCRIPT Line 8. 68.
[22] 6 MAY TRANSCRIPT Lines 4-6. 43.
[23] Trial Chamber. Transcript of Trial Proceedings (9 May 2013). E1/192.1 [hereinafter 9 MAY TRANSCRIPT] Lines 17-19. 18.
[24] Trial Chamber. Transcript of Trial Proceedings (8 May 2013). E1/191.1 [hereinafter 8 MAY TRANSCRIPT] Lines 9-10. 100.
[25] Abdulhak was referring to page 321-322 of “History”.
[26] 8 MAY TRANSCRIPT Line 15. 19. It should be noted that Philip Short tried to provide his opinion on whether genocide occured during the questioning of Judge Cartwright, but he was stopped because it was a legal label. This opinion was provided when Koppe, acknowledging that the determination whether Genocide occured duringDK regime was for the Judges to determine, quoted page 446 of “History” where it was stated that KR did not setout to exterminate a national, ethnic, racial, or religious group”. Koppe asked whether Short could provide his opinion why he maintained there was no such policy without using the “G” word.
[27] Abdulhak cited from page 132 of “History”.
[28] See ISSUE 29 and ISSUE 30.
[29] 6 MAY TRANSCRIPT Line 19. 53.
[30] Ibid. Line 6. 48.
[31] 7 MAY TRANSCRIPT Line 12. 25.
[32] Ibid. Line 14 p. 25.
[33] 9 MAY TRANSCRIPT Lines 14-19. 135
[34] Short stated that visiting leaders were Pol Pot, Ieng Sary, Vorn Vet, and Thioun Thioeunn.
[35] 6 MAY TRANSCRIPT Lines 9-11. 17
[36] Koppe used the word “president” but perhaps he was referring to Heng Samrin’s appointment as the chairman of the People's Revolutionary Council of the PRK in 1979.